**BMI0127**

### សម្ភាសន៍ជាមួយឈ្មោះ អ៊ិន ម៉ៅ ហៅ អ៊ិន សាម៉េន ភេទស្រី អាយុ៥១ឆ្នាំ

### មុខងារនៅសម័យខ្មែរក្រហមៈ កងចល័តស្រុក៣៣(ស្រុកព្រៃកប្បាស)

### មុខងារបច្ចុប្បន្នៈ កសិករ

### ស្រុកកំណើតនៅភូមិព្រៃដើង ឃុំគោកព្រេច ស្រុកគីរីវង់ ខេត្តតាកែវ

### សព្វថ្ងៃរស់នៅភូមិថ្មដែកកេះ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

### ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១០

### សម្ភាសន៍ដោយៈ ហ៊ិន សុធានី

### ០០:៥៩:១២

### ៣៨ទំព័រ

ធានី : ថ្ងៃនេះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១០ ។ ខ្ញុំឈ្មោះធានី ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំចុះនេះចង់សាកសួរមីង ពីប្រវត្តិរបស់មីងដែលមីងបានឆ្លងកាត់កាលពីសម័យដូចថាពីមុនៗមករហូតមកដល់ឥឡូវមីងណា៎ ។ ថាតើប្រវត្តិរបស់មីងម វនការលំបាកអីខ្លះ ជួបរឿងអី ខ្លះ ដែលមីងឆ្លងកាត់ណា ។

ម៉ៅ : ចា៎! មុនដំបូងពីឆ្នាំ៧៣ ៧៤ ខ្ញុំនៅកុមារភូមិទេៗ ប៉ុន្តែគេឲ្យយើងជួយយាម សែងរបួសកងទ័ព ។ មានពេលមួយយន្តហោះអាមេរិចវ៉ាទម្លាក់ ។

ធានី : ម៉េចទៅមីង និយាយទៅ?

ម៉ៅ : ចា៎! យន្តហោះគេហៅអាមិច វ៉ាទម្លាក់គៀនកងទ័ពនៅភូមិៗអឺ! ភូមិឃុំខ្លួនឯងភ្លេចបាត់មើល នៅឃុំអឺ!សោម ។

ធានី : ឃុំសោម?

ម៉ៅ : ចា៎!

ធានី : ភូមិអីគេ?

ម៉ៅ : ខ្ញុំភ្លេចភូមិ ដូចភូមិអីៗ ស្រុកខ្លួនឯង ភូមិខ្លួនឯង ហើយចេញទៅវ៉ាភ្លេច ។ ទម្លាក់ស្លាប់កងទ័ព កាលហ្នឹងគេហៅយៀកកុងទេប្អូន ។ គេហៅយៀកកុងស្លាប់អស់ច្រើនម៉ាកងវរសេនាធំ ។

ធានី : យៀកកុងអ្នកទម្លាក់ ឬក៏យើង?

ម៉ៅ : អាមេរិចទម្លាក់ ។

ធានី ៖ ទម្លាក់ត្រូវយៀកកុងហ្នឹង?

ម៉ៅ ៖ ចា៎!

ធានី ៖ ជាមួយមីងដែរ មីងនៅជាមួយយៀកកុងចឹង?

ម៉ៅ ៖ ចា៎! ខ្ញុំប្រជាជននៅក្នុងភូមិហ្នឹង ។

ធានី ៖ ប៉ុន្តែគេទម្លាក់ហ្នឹង ទម្លាក់ត្រូវយៀកកុងហ្នឹង?

ម៉ៅ ៖ ចា៎! នៅក្នុងស្រុកហ្នឹង ប៉ុន្តែឃុំដោយឡែកពីគ្នា ប៉ុន្តែសែងកងទ័ពមកយកមកកាប់នៅកំពែងហ្នឹង យើងឆ្លងកាត់ឃុំយើង ។ ចា៎! ក្រោយមកខ្ញុំចូលកងចល័តៗជីកៗអឺ! ប្រឡាយ នឹកប្រឡាយមិនឃើញ ។ ជីកប្រឡាយក្នុងម្នាក់អឺ!ម៉ាម៉ែត្រគីបកន្ទះ ក្នុងម្នាក់ បើអ្នកណាគេជីកក្នុងម៉ាម៉ែត្រគីបកន្ទះមិនរួចគេដាក់២ម៉ែត្រ ។ ហើយអ្នកដូចថាស្រឡាញ់គ្នា សម័យនោះយើងស្រឡាញ់គ្នា ខ្ញុំវានៅតូចៗដែរណា៎ បងៗស្រឡាញ់គ្នា ដូចថាគាត់ស្រឡាញ់មិនស្រឡាញ់ជា អីទេ គ្រាន់ថាស្រឡាញ់ឥឡូវគេថាស្ទី អឺ!គេថាខុសសីលធម៌សម័យនោះឲ្យគាត់រែកក្នុងម្នាក់ ៣ម៉ែត្រគីប បើមិនហើយគេមិនឲ្យហូបបាយ ។ អឺ! បើធ្វើការបិទភ្លឺក្នុងកុមារម្នាក់គេឲ្យបិទ ម្នាក់៥ម៉ែត្រ បើមិនហើយ៥ម៉ែត្រ គេដាក់៧ម៉ែត្រ ។

ធានី ៖ ម៉េចទៀតមីង?

ម៉ៅ ៖ អឺ! ស្ទូងក្នុងម៉ាហិចតាគេដាក់២០នាក់ បើមិនហើយគេដក៥នាក់ចេញ ។

ធានី ៖ ម៉េចចឹងមីង?

ម៉ៅ ៖ ដឹងកាលហ្នឹង ។

ធានី ៖ ម៉េចទៀតមីង?

ម៉ៅ ៖ ក្រោយមកខ្ញុំចូលកងទ័ពរហូត ។

ធានី ៖ ម៉េចទៀតមីង?

ម៉ៅ ៖ ចូលក្នុងកងទ័ពៗអត់ដឹងថាខាងក្រោយគេធ្វើអីៗទៀត អត់ដឹង ។

ធានី ៖ មីងនិយាយរឿងការងារនៅកងទ័ព?

ម៉ៅ ៖ ការងារក្នុងកងទ័ពក៏វាមិនអី គេប្រើតែទូលគ្រាប់ចូលសមរភូមិក៏វាមិនឃើញជាលំបាកអី ។

ធានី ៖ ម៉េចទៀតមីង?

ម៉ៅ ៖ ការងារក្នុងកងទ័ព ដូចខ្ញុំថាចឹងចូលកងទ័ពយើងមានកម្លាំងគេចេះតែប្រើយើងទៅ ដល់យើងអន់ថយកម្លាំង ។ ពេលខ្ញុំធ្វើកងទ័ពខ្មែរក្រហមថាអត់អីហូប ដូចមិនមាន សម័យនោះណាប្អូនដូចមិនមានអត់ ។ មក៧៩ឃើញអត់ និយាយទៅទើបតែមកតូចចិត្តសម័យឥឡូវនេះតែម្តង

ពីមុនមក ខ្ញុំនៅកង់ទ័ពវាស្រួលតែរហូត យើងវាមិនដឹងថាខាងក្រោយហ្នឹងអត់ឃ្លានហើយយ៉ាងណាយ៉ាងណែ គេវ៉ៃគេសម្លាប់អីក៏វាមិនដឹង ។ យើងដឹងថាគេប្រើឲ្យបាញ់គ្នា ក៏បាញ់គ្នា វាមិនដឹងថាយ៉ាងណាយ៉ាងណែ ។ ប៉ុនចេះប្អូនសំណួលពរថា កងទ័ពឥឡូវ និងកងទ័ពពីមុន ខ្ញុំនិយាយបើខុស ប្អូនឯងកុំប្រកាន់ ខ្ញុំអ្នកស្តាប់មិនដឹងទេណា ។ កងទ័ពឥឡូវ និងកងទ័ពពីមុនៗ ដែលគ្នាខំតស៊ូដូចគ្នា យើងថាជួយជាតិដូចគ្នាមិនចឹងប្អូន មួយថាជាតិៗប៉ុន្តែដល់តែអ្នករួចហ៊ុនសែនថា គ្មានអ្នកឈ្នះ គ្មានអ្នកចាញ់ ដែលត្រង់ហ្នឹងហើយមេៗឈ្លាតថាឈ្មោះទាហានពិតគ្នាអត់បានប្រាក់ខែសុី ដែលអ្នកអត់ធ្វើទាហានបានប្រាក់ខែសុី ។ ដូចអ្នកខ្លះពិការដើរលេងគ្រាប់លេងបេបានរបបសុី ។ ដល់គ្នាពិការមែន គ្នាមិនដឹងថាកង គេប្រមូលកូនកងកូនក្រុមមេហ្នឹងអត់ប្រមូល គេប្រមូលតែបងប្អូនគេដាក់ អ្នកគ្នាតស៊ូពិតប្រាកដគ្នាអត់វាចេះ ។ តែអាហ្នឹង អ្នកណាក្តាប់អ្នកណាយ៉ាងណាអាហ្នឹងគ្រាន់តែចង់ដឹងតែប៉ុនហ្នឹង ។ អាហ្នឹងគេថាអ្នកឡើងបាន តែបេះ អ្នកនៅក្រោមគេប្រលេសបានហូបមែន ដូចពាក្យស្លោកគេថាមិនខុសទេ ។

ធានី : មីងឮពាក្យស្លោកហ្នឹងយូរនៅ?

ម៉ៅ : ទេ! ខ្ញុំកើតមកឮថាតាមតែគេចឹងដែរ ។

ធានី : ខ្ញុំអត់សូវដឹងដែរ ។

ម៉ៅ : ចា៎! ខ្ញុំមិនដឹងដែរ ខ្ញុំឮតាមគេដែរ ។

ធានី : រឿងអស់ហ្នឹងខ្ញុំអត់សូវដឹងដែរមីង ព្រោះអីពួកខ្ញុំគ្រាន់តែជាអ្នកស្រាវជ្រាវ ។

ម៉ៅ : ចា៎! ស្រាវជ្រាវខ្ញុំមិនដឹង ខ្ញុំមើលឃើញនឹងភ្នែក ។

ធានី : ចា៎! ហ្នឹងហើយជាការលំបាកមួយដែរ របៀបថាកងទ័ពយើងខំតស៊ូ ចុងក្រោយវាអត់បានអីសោះចឹងមីង ។ រឿងហ្នឹងខ្ញុំបានត្រឹមតែដឹងទេ ហើយខ្ញុំ ។

ម៉ៅ : ហើយរឿងពុករលួយមិនដឹងរលួយត្រឹមប៉ុន្មានទេខ្ញុំមិនដឹងទេណា អានេះយើងនិយាយ ។

ធានី : ចា៎! ខ្ញុំអត់ដឹងដែរ ។

ម៉ៅ : ចា៎! អានេះយើងនិយាយតាមកំហឹងដែលយើងខឹង ដូចថាអ្នកខំឡើង បានតែលះផ្លែមក អាត្រង់ថាផ្អែមមិនផ្អែមគេអ្នកនេះគេបេះសុី ។ នេះហើយថាសម័យនោះគេបញ្ឆលយើងយកតែ កម្លាំង ។

ធានី : ចឹងមីងសោកស្តាយអត់?

ម៉ៅ : វាហួសនិយាយហើយប្អូន ។

ធានី : និយាយទៅតាំងពីមីងចូលបដិវត្តរហូតមកដល់ឥឡូវ តើមីងមានអារម្មណ៍សោកស្តាយដែលខំប្រឹងតស៊ូ តែចុងក្រោយអត់មានបានអីទាំងអស់?

ម៉ៅ : ចុងក្រោយគ្មានស្អី បានតែឈឺ ។

ធានី : បានតែឈឺម៉េច?

ម៉ៅ : ចុងក្រោយវាមានលទ្ធផលអីហ្នឹងបាន ដូចមិនមាន ។

ធានី : តើមីងគិតថាមានការសោកស្តាយអីអត់ បើសិនជាពេលហ្នឹង មីងកុំចូលធ្វើជាទាហានធ្វើអីហ្នឹង?

ម៉ៅ : បើមិនធ្វើយើងនៅក្រោមអាណាព្យាបាលរបស់គេ យើងគេចមិនរួច ។

ធានី : តែចង់និយាយថាចិត្តរបស់មីង មីងផ្ទាល់បើសិនជាអាចគេចរួច តើមីងហ្នឹងអាចថាអត់ធ្វើអីចឹង ស្តាយក្រោយទេ ពាក្យថាស្តាយក្រោយ?

ម៉ៅ : ស្តាយក្រោយៗហើយ តែយើងវានិយាយវាមិនរួច ។

ធានី : ហេតុអីទៅមីង?

ម៉ៅ : យើងដូចថាយើងនៅផ្ទះម៉ែយើងចឹង ម៉ែយើងប្រើឲ្យយើងទៅរកអុស បើយើងមិនទៅរកអុស វាត្រូវរំពាត់ ត្រូវតែទៅ យើងនិយាយឲ្យខ្លីចឹង ។

ធានី : សរុបទៅអត់ស្តាយក្រោយទេ?

ម៉ៅ : វាស្តាយក៏វាហួសពីស្តាយហើយប្អូន និយាយវាមិនបានដដែល ។

ធានី : ប៉ុន្តែគ្រាន់វាមានអារម្មណ៍ថាស្តាយក្រោយដែរ ខំតស៊ូ?

ម៉ៅ : វាអន់ចិត្ត បានម៉ាតូចចិត្ត វាមិនបានមានន័យអីប្អូន ។

ធានី : ខំតស៊ូនឹងគេដែរ?

ម៉ៅ : ចា៎! តស៊ូហ្នឹងគេអី គេពីដើមគេប្រើយើងសុទ្ធតែប្អូនល្អៗណាស់ ដល់ឥឡូវគេបានលុចស៊ីស គេជិះបង្ហុយសាចទឹកដាក់ឯង គេមិនមើលយើងដែរ ។

ធានី : ចឹងខ្ញុំសុំសួរបកក្រោយតិចណា កាលពេលឆ្នាំ៧៣ ៧៤ហ្នឹង មីងធ្វើការងារអីគេ អ្នកសែងរបួស?

ម៉ៅ : ចា៎! ខ្ញុំនៅភូមិ កុមារភូមិរៀនក្រោមដើមឈើផង ធ្វើជីផង ដល់យប់សែងរបួស ។

ធានី : សែងរបួស?

ម៉ៅ : ចា៎! ដូចថាកងទ័ពវ៉ៃសមរភូមិចឹងទៅ មានរបួស មានស្លាមចឹងទៅ ។

ធានី : កាលហ្នឹងមីងអាយុប៉ុន្មាន កុមារភូមិហ្នឹង?

ម៉ៅ ៖ ចាំ! កុមារភូមិខ្ញុំអាយុ១៨ ១៩ ។

ធានី ៖ ១៨ ទៅ១៩ឆ្នាំ?

ម៉ៅ ៖ ចាំ!

ធានី ៖ កាលហ្នឹងម៉េចបានមីងទៅចូលធ្វើជាកុមារភូមិ?

ម៉ៅ ៖ ចាំ! ព្រោះអីភូមិខ្ញុំនៅតាមថ្នល់ជាតិចឹង តែសែងរបួសមកត្រូវដាក់ស្នាក់ការតាមហ្នឹងរហូត ។

ធានី ៖ ចឹង?

ម៉ៅ ៖ ចាំ! ឧបមាថាសែងចេញពីភូមិខ្ញុំទៅភូមិគេផ្សេង ដាក់ស្នាក់ការក្នុងម៉ាភូមិរោងយាម២ ហើយ
គេចាប់គេញអាមេរិចកាំង គេហៅសេ.អ៊ី.អា គេចាប់ពួកគេអូហៅកាប៉ាល់ហោះទម្លាក់ ។

ធានី ៖ ហើយចឹង ភូមិមីងនៅកណ្ដាល ដែលថាធ្វើសង្គ្រាមហ្នឹង?

ម៉ៅ ៖ មិនមែនតែភូមិខ្ញុំទេ
ឲ្យតែនៅតាមថ្នល់ជាតិចេញពីយើងពីសមរភូមិមកសែងតាមថ្នល់ជាតិហ្នឹង
គ្រប់ភូមិគ្រប់ឃុំគ្រប់ស្រុកទាំងអស់សែង ។

ធានី ៖ ចឹងឲ្យតែនៅស្រុកគីរីវង់ ស្រុក១០៩ហ្នឹងគេធ្វើចឹងទាំងអស់?

ម៉ៅ ៖ ចាំ! ឲ្យតែតាមផ្លូវក្នុងភូមិហ្នឹងគេផ្លាស់វេណគ្នា ក្នុងម៉ាភូមិគេធ្វើបានតែ២ ៣វេណទេ ។

ធានី ៖ តែគេឲ្យកុមារៗដូចជាមីងហ្នឹងធ្វើ?

ម៉ៅ ៖ អ្នកនៅខាងក្រោយ មិនថាមនុស្សចាស់ ហើយកុមារ ហើយក៏នារីដែរ ឲ្យតែអ្នកនៅខាង
ក្រោយជួយគ្នា ។

ធានី ៖ ឲ្យនៅខាងក្រោយ?

ម៉ៅ ៖ ចាំ! ឧបមាថាក្នុងម៉ាក្រុមហ្នឹងមានកុមារប៉ុន្មាននាក់ មាន៣-៤នាក់ចឹងទៅជួយសែងគ្នា ។

ធានី ៖ ចឹងមីងកាលហ្នឹងអ្នកណាគេអ្នកដឹកនាំក្នុងភូមិយើង?

ម៉ៅ ៖ ចាំ! ភូមិហ្នឹង យាយបូ គណៈស្រុក ។

ធានី ៖ យាយបូ?

ម៉ៅ ៖ ចាំ! គណៈស្រុក ឈ្មោះបូ ។

ធានី ៖ អូ! យាយបូគណៈស្រុក ។ ឆ្នាំប៉ុន្មាន៧៣ ៧៤ហ្នឹង?

ម៉ៅ ៖ អឺ! ៧៣ ៧៤ហ្នឹង គេហៅ គេមិនមែនហៅនេះទេ គេហៅមេ១០០ខ្នង មេ៥០ខ្នងអីទេ ។

ធានី ៖ អូ! ចឹងយាយបូហ្នឹងមេអីគេទៅ?

ម៉ៅ ៖ មេ យាយបូមេ៧៥ទេប្អូន ។

ធានី ៖ អឺ! យាយបូ?

ម៉ៅ ៖ ចាំ! យាយបូគណៈស្រុក៧៥ទេ ។

ធានី ៖ យាយបូគេហៅគណៈស្រុក៧៥ចឹង?

ម៉ៅ ៖ ទេ!

ធានី ៖ គណៈស្រុកនៅឆ្នាំ១៩៧៥?

ម៉ៅ ៖ ចាំ!

ធានី ៖ ចឹងគណៈស្រុកលេខប៉ុន្មានទៅ?

ម៉ៅ ៖ មិនដឹងលេខប៉ុន្មានទេ ខ្ញុំមិនយកចិត្តទុកដាក់ផង អត់យកចិត្តទុកដាក់ទេ ។

ធានី ៖ ហើយចឹងម៉េចមីងដឹងថាយាយបូហ្នឹង គាត់ប្រធាននៅហ្នឹង?

ម៉ៅ ៖ ឮតែគេថាមិនដែលឃើញឈ្មោះផង ។

ធានី ៖ តែកាលពេលមុន៧៣ ៧៤ ក៏អត់ដឹងគាត់នៅហ្នឹងដែរ?

ម៉ៅ ៖ ចាំ!

ធានី ៖ ដល់ពេលឡើង៧៥ប៉ុបបានគេប្រកាសថាយាយបូ?

ម៉ៅ ៖ ចាំៗ ។

ធានី ៖ ហើយចឹងម៉េចទៀតទៅមីង ពេលដែលមីងមិញបន្ទាប់មកមីងគេថាមីងគេឲ្យជីកប្រឡាយ ជីក អីអាហ្នឹងឆ្នាំ៧៥ហើយ?

ម៉ៅ ៖ ហ្នឹង៧៥ហើយ ។

ធានី ៖ ពេលយាយបូចូលមកនៅហើយ?

ម៉ៅ ៖ ចាំ!

ធានី ៖ ចឹង៧៣ ៧៤ហ្នឹងគឺ ចឹងពេលណាខ្មែរក្រហមចូលមកដល់ភូមិយើង?

ម៉ៅ ៖ អូ! ពួកខ្ញុំ គេមិនហៅខ្មែរក្រហមទេ គេហៅយៀកកុងកាល៧១ ៧២នេះ គេហៅយៀកកុងទៅ ។

ធានី ៖ ចឹងពួកខាងប្រជាជនយើងដែលរស់នៅខាងហ្នឹង គេហៅយៀកកុងទាំងអស់គ្នា?

ម៉ៅ ៖ ចាំ! ហៅយៀកកុងៗត្រូវគ្នាជាមួយយួន ។

ធានី ៖ ចង់និយាយថាយៀកកុងហ្នឹងហើយម៉េចបានចេញទៅខ្មែរក្រហមគេហៅ?

ម៉ៅ ៖ ខ្ញុំមិនសូវដឹងដែរ ព្រោះអី៧៥គេរំដោះអឺ!គេហៅស្ពីរណាសិរ្សស្ពីណា ខ្ញុំមិនយល់ ។

ធានី ៖ មិនសូវដឹងដែរ?

ម៉ៅ ៈ ចា៎! ខ្ញុំមិនយកចិត្តទុកដាក់ ។

ធានី ៈ ប៉ុន្តែគ្រាន់ដឹងថាដំបូងយៀកកុង តែដល់ក្រោយទៅពីយៀកកុងគេហៅខ្មែរក្រហមចឹង?

ម៉ៅ ៈ ហ្នឹងហើយគេហៅរណសិរ្សស្អីគេ ខ្ញុំមិនចាំដែរ ។

ធានី ៈ ខ្មែរសេរីស្រះ?

ម៉ៅ ៈ អត់ទេ យៀកកុងហើយបានគេហៅ មិនដឹងគេហៅស្អីគេទេ ភ្លេចហើយ ។

ធានី ៈ ភ្លេចហើយមីង?

ម៉ៅ ៈ ចា៎!

ធានី ៈ ហើយចឹងពេលខ្មែរក្រហមចូលមក បានយាយបូគាត់ឡើងប្រកាសទៅ ដូចថាមីងធ្វើ?

ម៉ៅ ៈ ចា៎! នៅ១៧មេសាហើយ បានគេឃើញគេហៅៗស្អី គេហៅទៅប្រជុំគេហៅស្អីទេអ៊ី ។

ធានី ៈ ប្រជុំ ហើយមេទិញ?

ម៉ៅ ៈ អឺ! មេទិញ គេហៅមេទិញ ។

ធានី ៈ មេទិញ១៧មេសា?

ម៉ៅ ៈ ចា៎! គេហៅមេទិញនៅនោះទៅ គេប្រកាសប្រាប់ ។

ធានី ៈ ប្រកាសថាម៉េចខ្លះមីង?

ម៉ៅ ៈ គេប្រជុំមិត្តនេះ មិត្តនោះ ឈ្មោះនេះឈ្មោះនោះមកកាន់ស្រុកគិរីវង់អីចឹងទៅណា មាន ប្រធានយុវ្វជន ប្រធាននារីអីហ្នឹងគេ ។

ធានី ៈ ចុះកាលហ្នឹងមីងមានបានធ្វើអីហ្នឹងគេទេ?

ម៉ៅ ៈ ចា៎! ធ្វើអី ។

ធានី ៈ ធ្វើប្រធានយុវ្វជនអីហ្នឹងគេទេ?

ម៉ៅ ៈ ប្រធានអី នៅកុមារហ្នឹង ។

ធានី ៈ មិនមែនធ្វើប្រធានកុមារទេ?

ម៉ៅ ៈ អត់បានធ្វើទេ យើងស្អីយើងបងប្អូនធ្វើទាហានធ្វើប៉ូលិស ។

ធានី ៈ មីងមានបងប្អូនធ្វើទាហានដែរ?

ម៉ៅ ៈ ចា៎! អុំខ្ញុំគេចង់ហ្នឹងអំបោះ បណ្តើររហូត ។

ធានី ៈ ម៉េចចឹងមីង?

ម៉ៅ ៈ អឺ! យើងប៉ូលិស ។

ធានី ៈ អុំមីងហ្នឹងគាត់ឈ្មោះអីគេ?

ម៉ៅ : ចា៎! អ៊ំខ្ញុំគាត់ធ្វើប៉ូលីស ។

ធានី : អ៊ំឈ្មោះអីគេ?

ម៉ៅ : ឈ្មោះ ចាន់ ។

ធានី : អីគេចាន់?

ម៉ៅ : ដឹងដែរ ដឹងគាត់ដាក់ត្រកូលអី ។

ធានី : គាត់ប៉ូលីសអី?

ម៉ៅ : ប៉ូលីសនៅខេត្តៗមិនដឹងថាអី តាខ្ញុំបានគាត់ចាំច្រើន ខ្ញុំដូចថាមិនយកចិត្តទុកដាក់ គេប្រើចេះប្រើទៅ ចេះថៃទៅ ។

ធានី : ចឹងមីង អ៊ំរបស់មីងធ្វើប៉ូលីសខាងលន់ នល់ តែអត់ដឹងសក្តិប៉ុន្មានទេ ដឹងគាត់ធ្វើទាហានអីៗ?

ម៉ៅ : ដឹងសក្តិអីទេ ។

ធានី : អត់ដឹង ចុះម៉េចបានមីងដឹងថាគាត់ធ្វើទាហាន?

ម៉ៅ : ចា៎! ខ្ញុំទៅកន្លែងគាត់ ។

ធានី : ទៅកន្លែងគាត់?

ម៉ៅ : គាត់ប្រជុំជួរ ចែកលុយចែកកាក់អីគាត់អ្នកចែក ។

ធានី : អ៊ំរបស់មីងហ្នឹង ។

ម៉ៅ : ចា៎!

ធានី : នៅកាលឆ្នាំប៉ុន្មានដែលមីងទៅហ្នឹង?

ម៉ៅ : កាលខ្ញុំទៅគេអត់ទាន់វ៉ៃបែកផង ។

ធានី : ហ្នឹងហើយកាលហ្នឹងឆ្នាំប៉ុន្មាន?

ម៉ៅ : មិនដឹងជាឆ្នាំ៧០ប៉ុន្មាន មិនដឹងដែរលន់ នល់មិនទាន់វ៉ៃបែកណា លន់នល់នៅតើ កាប៉ាល់ហោះមិនទាន់ទម្លាក់ណា ។

ធានី : មីងទៅហើយបានចាប់ផ្តើមបានគេចាប់អ៊ំមកស្រុកភូមិយើងវិញ?

ម៉ៅ : ទេ! ដល់៧៥ ។

ធានី : ហ្នឹងហើយដល់៧៥ហ្នឹងម៉េចទៅមីង គេចាប់អ៊ំមកស្រុកវិញ ឬក៏គាត់មកខ្លួនឯងគេចាប់មក?

ម៉ៅ : គេចាប់មក ។

ធានី : ចាប់មកគេប្រកាសនៅក្នុងមេទិញហ្នឹងដែរ?

ម៉ៅ ៖ អត់ប្រកាសមេចិញហ្នឹងទេ ចង់ដើរតាមហ្នឹងរាប់រយនាក់តែម្ដង ។

ធានី ៖ ប៉ុន្មានរយនាក់ទៅមីង?

ម៉ៅ ៖ មិនដឹងជាប៉ុន្មានរយនាក់ដែរ ឃើញផ្ទះ(ផ្ទាល់) ក៏ចូលមិនបាន ។

ធានី ៖ ម៉េចចឹងមីង?

ម៉ៅ ៖ ចុះបើគេចង់ហ្នឹងអំបោះដាច់ត្រឹមន្មានបាញ់ចោលត្រឹមហ្នឹង ។

ធានី ៖ អូ! គេប្រាប់ចឹង?

ម៉ៅ ៖ ចាំ!

ធានី ៖ ខាងណាអ្នកចង់មីងដឹង?

ម៉ៅ ៖ ខាងហ្នឹងឯង ខាងគេហៅខ្មែរក្រហមហ្នឹង ។

ធានី ៖ ដូចថាខាងយាយបូហ្នឹង?

ម៉ៅ ៖ ទេ! កងទ័ពរំដោះ យាយបូគាត់កាន់ប្រជាជនតើ ។

ធានី ៖ ចឹងខាងទ័ពរបស់ខ្មែរក្រហមផ្សេងទៀត មិនមែនយាយបូទេ?

ម៉ៅ ៖ ចាំ! កងទ័ពខ្មែរក្រហមគេផ្សេងទៀត គេបណ្ដើរមកឈ្លបគេណាំ ។

ធានី ៖ អត់ស្គាល់ឈ្មោះគេទេ?

ម៉ៅ ៖ អត់ស្គាល់ទេប្អូនយើងមិនយកចិត្តទុកដាក់ ។

ធានី ៖ ហើយដល់ពេលហើយ ពេលហ្នឹងមីងកំពុងធ្វើអី?

ម៉ៅ ៖ ចាំ! ខ្ញុំ អឺ!កាលពេលហ្នឹងក៏ខ្ញុំ មិនវេណ យើងឈប់យាមហើយ យើងនៅតាមភូមិធម្មតា ធ្វើស្រែធ្វើចំការ ។

ធានី ៖ តាមភូមិធម្មតា?

ម៉ៅ ៖ ចាំ! យើងគេឲ្យធ្វើស្រែធ្វើអីវិញហើយណាប្អូន ធ្វើក្រុមប្រវាសដៃកាលហ្នឹង ។ អុំខ្ញុំ និយាយទៅពោះដាមួយឪខ្ញុំនិយាយទៅទាហានទាំងអស់ ។ ដល់ចឹងក្រុមគ្រួសារខ្ញុំ គេអត់ឲ្យទោះបីគេចែកក្រណាត់ចែកអីក៏មិនដែលបានហ្នឹងគេដែរ ព្រោះអីយើងអតីត ។ ខ្ញុំបងប្អូនខ្ញុំ គាត់ធ្វើទាហានធ្វើប៉ូលីសទាំងអស់ ដល់ចឹងយើងអត់មានសិទ្ធិអីដឹងថាក្នុងចង្កោម ។ ទោះបីគេប្រជុំៗយកតែក្រីក្រគេប្រជុំស្ងាត់ផ្សេង ។ ហើយយើងអ្នកក្រុមគ្រួសារទាហានប៉ូលីស គេហៅ ១៧ មេសា ។

ធានី ៖ ចឹងមីងបញ្ជោសគ្នាវិញ?

ម៉ៅ ៖ ចាំ!

ធានី ៖ ចឹងមីងត្រូវ១៧ ចុះម៉េចបានមីងបានចូលធ្វើទ័ព?

ម៉ៅ ៖ ចាំ! ធ្វើទ័ពយើង កាលយើងដល់ពេលសែនវបួសហើយ យើងនៅក្នុងភូមិកេត្រូវតែប្រើវាអត់ កម្លាំង ។

ធានី ៖ វាប្រើៗឲ្យចូលធ្វើទ័ពវិញ?

ម៉ៅ ៖ ដល់ខ្ញុំចូលធ្វើទ័ពនេះ អានេះ៧៥ហើយតើ ។

ធានី ៖ ហ្នឹងហើយ ៧៥ហ្នឹងមីងចូលធ្វើទ័ពវិញ?

ម៉ៅ ៖ ខ្ញុំចល័ត ។

ធានី ៖ ចល័តៗហើយម៉េចទៀតទៅ?

ម៉ៅ ៖ ចល័តហើយបានចូលទៅយួនវ៉ៃខ្លាំងទៅបានគេបំបែកចល័តឲ្យចូលធ្វើទ័ព អាហ្នឹងគេលែងរើសហើយ ។

ធានី ៖ អូ! ចឹងកាលពេលមីងចល័តហ្នឹងចល័តអីគេ?

ម៉ៅ ៖ ខ្ញុំនៅចល័តតំបន់ ។

ធានី ៖ ចល័តតំបន់គីរីវង់ហ្នឹង?

ម៉ៅ ៖ តំបន់គេហៅតំបន់១៣ ។

ធានី ៖ តំបន់១៣?

ម៉ៅ ៖ ចាំ!

ធានី ៖ ចឹងមីងចល័តជុំវិញតំបន់ហ្នឹង ។ តំបន់ហ្នឹងមានប៉ុន្មាន ស្រុកយើង កាលសម័យហ្នឹងមានប៉ុន្មានស្រុក?

ម៉ៅ ៖ ដឹងប៉ុន្មានស្រុកទេប្អូន ខ្ញុំដូចថាខ្ញុំប្រាប់ខ្ញុំមិនដែលយកចិត្តទុកដាក់ទេ គេប្រើឲ្យជីកប្រឡាយជីកទៅ មិនដឹងថាយើងអតីតយើងអាក្រក់គេមិនឲ្យយើងដឹងទេ ។

ធានី ៖ ចឹងអាហ្នឹងមីងខិតខំប្រឹងតែធ្វើការធ្វើស្រែ មិនដឹងគេម៉េចៗ?

ម៉ៅ ៖ ចាំ!

ធានី ៖ ដូចមីងនិយាយចឹង?

ម៉ៅ ៖ រឿងគេប្រជុំខុសអីៗយើងមិនដឹងទេ ។

ធានី ៖ ដូចមីងថាចល័តជីកប្រឡាយរឿងម្នាក់ឲ្យម៉ាថ្ងៃ បើអត់បានគេដាក់២ម៉ែត្រគូបចឹង?

ម៉ៅ ៖ ចាំ!

ធានី ៖ ហើយជីកប្រឡាយនៅណាខ្លះទៅ?

ម៉ៅ ៖ ចា៎! ខ្ញុំដឹកនៅកំពែងហ្នឹង លើកទី១ លើកទី២ខ្ញុំដឹកពីអន្លុងវែង អន្លុងវែងយើងឯជិតភ្នំដា ដឹកខ្សែ ដីក គេហៅ០៥ ប្រឡាយ០៥ ។

ធានី ៖ ប្រឡាយ០៥ អាហ្នឹងលើកទី២?

ម៉ៅ ៖ ច្រើនលើកប្អូន នៅមកស្រុកត្រាំកក់នេះទៀត ។

ធានី ៖ ស្រុកត្រាំកក់យ៉ាងម៉េច?

ម៉ៅ ៖ ស្រុកត្រាំកក់ក៏ដឹកប្រឡាយដូចគ្នា វាដឹកត្រឡប់ត្រឡិនៗ យើងចល័តគេហៅស្រេចតែគេហៅ ដាក់ រាប់កន្លែងមិនអស់ទេ ។

ធានី ៖ ចុះមីងមិញថាក្រៅពីដឹកប្រឡាយមានធ្វើអីទៀតទេ?

ម៉ៅ ៖ ចា៎! ធ្វើស្រែ ។

ធានី ៖ ស្ងួនម៉ាហិចគាៗ?

ម៉ៅ ៖ ចា៎! ធ្វើស្រែ ។

ធានី ៖ ម៉ាហិចគាឲ្យបាន២០នាក់យ៉ាងម៉េច?

ម៉ៅ ៖ ហ្នឹងហើយ ។

ធានី ៖ អាហ្នឹងមានគេធ្វើចឹងទៀត?

ម៉ៅ ៖ ចា៎!

ធានី ៖ ចឹងមីងថាបានដឹងថារឿងខុសសីលធម៌ ដឹងថាអ្នកណាជាមួយអ្នកណាដែលខុសសីលធម៌ដែល គេដាក់ពិន័យ?

ម៉ៅ ៖ អឺ! កាលហ្នឹងគេនារីៗកំពែងហ្នឹងឯង យុវជនកំពែង ។

ធានី ៖ ឈ្មោះអីគេ?

ម៉ៅ ៖ អត់ស្គាល់គេទេប្អូន ដូចខ្ញុំប្រាប់ចឹងយើងអ្នកមិនល្អគេមិនឲ្យដឹងការងារគេទេ ដូចដឹកប្រឡាយ ចឹង ។

ធានី ៖ ចុះមីងដឹងថាគេយកគាត់ទៅសម្លាប់អត់?

ម៉ៅ ៖ ខ្ញុំអត់ដឹងទេ ដឹងថាគេដាក់ទោសគាត់ឲ្យកោរត្រងោល ហើយរែកដី ។

ធានី ៖ ទាំងពីរនាក់កោរត្រងោល?

ម៉ៅ ៖ ចា៎!

ធានី ៖ ហើយដល់ពេលបន្ទាប់មកទៀតមីងទៅធ្វើដល់ឆ្នាំប៉ុន្មាន បានមីងទៅធ្វើទ័ព?

ម៉ៅ ៖ ចា៎! អឺ!៧៥ខ្ញុំចូលកងចល័តតំបន់ហ្នឹង ដល់ចល័តតំបន់ហ្នឹងហើយ ខ្ញុំទើបចូលទ័ពបានប៉ុន្មានខែហ្នឹងគេ យួនវៃហ្នឹងទៅ។

ធានី ៖ ប្រហែលប៉ុន្មានខែ មីងនៅចាំ?

ម៉ៅ ៖ ខ្ញុំមិនដឹងដែរ។

ធានី ៖ ៧៨ ហើយឬនៅ ៧៨ ៧៩?

ម៉ៅ ៖ ៧៧។

ធានី ៖ ៧៧ មីងចូលធ្វើទ័ព ស្ម័គ្រចិត្តចូលធ្វើទ័ពទៅវៃណាខ្លះទៅ?

ម៉ៅ ៖ មិនបានវៃអីទេ គ្រាន់តែ។

ធានី ៖ នៅជួយអីគេ ជួយ?

ម៉ៅ ៖ នៅជួយដឹកជញ្ជូនគ្រាប់។

ធានី ៖ ដឹកជញ្ជូនគ្រាប់ពីណាទៅណាមីងដឹងទេ?

ម៉ៅ ៖ ពីអឺ! យើងនេះជូនពីអឺ! យើងជិតអឺ សួរគា ខ្ញុំមិនចាំភូមិគេ។

ធានី ៖ នៅខេត្តណាមីង?

ម៉ៅ ៖ ចា៎! នៅកំពង់ឆ្នាំង។

ធានី ៖ អឺ!នៅកំពង់ឆ្នាំ ម្តុំសាលាលេខ៥?

ម៉ៅ ៖ សាលាលេខ៥លេខអី មិនសូវដឹងទេ។

ធានី ៖ មិនសូវដឹង?

ម៉ៅ ៖ ចា៎! តាមៗគេហើយ។

ធានី ៖ ជញ្ជូនគ្រាប់ហ្នឹងនៅខេត្តកំពង់ឆ្នាំងហើយ?

ម៉ៅ ៖ ចា៎! សួរកងវរៈកងអីដូចមិនសូវចាំ ព្រោះអីខ្ញុំពុលថ្នាំកាលយើង៧៦។

ធានី ៖ អូ! ៧៦ ពុលថ្នាំម៉េចមីង?

ម៉ៅ ៖ ពុលថ្នាំមេវាក្បត់នោះដល់ចឹងរាល់ថ្ងៃហ្នឹង ក៏និយាយវាចងចាំមិនច្បាស់ដែរ និយាយទៅដូចមនុស្សលាយហើយ ខ្ញុំនិយាយឲ្យខ្លីទៅ។

ធានី ៖ ពុលថ្នាំក្បត់ម៉េចទៀត?

ម៉ៅ ៖ មេក្បត់គេដាក់បាយបំពុលក្នុងកងហ្នឹង ឲ្យយើងរាគ ឲ្យយើងរុះឲ្យអីស្លាប់ខ្លះ។

ធានី ៖ កាលហ្នឹងហូបបាយកងចល័តហ្នឹង?

ម៉ៅ : អឺ! គេធ្វើ១៧មេសា អាថ្ងៃគេបុណ្យថ្ងៃគេរំដោះ ដូចយើងធ្វើ៧មករាហ្នឹងចឹង ហើយយើងអត់បាយចឹង គេដាំបាយកាប់គោកាប់អីចឹងជប់លៀង ដល់ចឹងមានមេក្បត់វាដាក់ថ្នាំក្នុងសម្ល ក៏ឈឺ ពុល ។

ធានី : ពុលប៉ុន្មាននាក់ទៅ?

ម៉ៅ : អូ! ២កងវរៈ ពុលរាគ ។

ធានី : ប៉ុន្មានដែរទៅ?

ម៉ៅ : មិនដឹងប៉ុន្មានរយ ។

ធានី : ម៉ាកងវរៈហ្នឹងប៉ុន្មានកង ប៉ុន្មាននាក់?

ម៉ៅ : មិនដឹងជាប៉ុន្មានទេ ប្អូនដូចខ្ញុំថាចឹង ខ្ញុំមិនសូវចងចាំទេ ដល់ពេលពុលថ្នាំចឹង ខ្ញុំច្រើននិយាយពីមុខត្រឡប់ទៅក្រោយ ។

ធានី : ចឹងមីងពុលថ្នាំហ្នឹងខាងណាអ្នកដាក់?

ម៉ៅ : មេកង ។

ធានី : មេកងៗឈ្មោះអីគេ?

ម៉ៅ : មេកងតំបន់ឈ្មោះ ខន ឈ្មោះ នន គេហៅកង គាត់ប្រធានខន ។

ធានី : ខន នន?

ម៉ៅ : ហ្នឹងហើយ ។

ធានី : នន ២នាក់ហ្នឹងជាមេកងតំបន់ ហើយជាអ្នកដាក់ថ្នាំពុលហ្នឹង ។ ហើយចាប់បានទេ?

ម៉ៅ : គេចាប់បាន មិនដឹងគេបញ្ជូនគេហៅទៅលើៗ មិនដឹងលើណា អត់ដឹងដែរ ។

ធានី : អត់ដឹងគេបញ្ជូនទៅណា? មីងស្គាល់គុកព្រះធាតុអត់?

ម៉ៅ : វត្តព្រះធាតុ?

ធានី : ហ្នឹងហើយ ។

ម៉ៅ : អាហ្នឹងខ្ញុំស្គាល់ដែរ ភូមិខ្ញុំប៉ុន្តែគេមិនបញ្ជូនទៅហ្នឹងផង គេបញ្ជូនមកចន្ទុំវិញ ។

ធានី : មកចន្ទុំវិញ?

ម៉ៅ : ចា៎!

ធានី : ភ្នំចន្ទុំហ្នឹង?

ម៉ៅ : ចា៎!

ធានី : ចុះម៉េចបានគេបញ្ជូនទៅខាងហ្នឹងវិញ?

ម៉ៅ ៖ ហ្នឹងផ្នែកកងចល័ត ។

ធានី ៖ អូ! ផ្នែកកងចល័តគេបញ្ជូនទៅចន្លុង ដល់ពេលផ្នែកអីគេ បានមកព្រះធាតុហ្នឹងមីង?

ម៉ៅ ៖ ខ្ញុំមិនដឹងដែរ បើខ្ញុំអត់បាននៅព្រះធាតុផង បើការខ្ញុំពុល១ នៅបន្ទាយឆ្ងាយ អឺ!ថ្នស ។

ធានី ៖ ថ្នស អឺ!មីងពុលថ្នាំនៅថ្នសហ្នឹងទេ?

ម៉ៅ ៖ ចាំ!

ធានី ៖ ដល់ពេលចាប់គាត់មកយកមកចូលមកចន្លុង១ ?

ម៉ៅ ៖ ហ្នឹងហើយ មិនមែនចាប់ខ្ញុំទេ ចាប់មេដាក់ថ្នាំហ្នឹង ។

ធានី ៖ ហ្នឹងហើយចាប់អ្នកដែលដាក់ថ្នាំហ្នឹង ខ្ញុំចង់សួរអ្នកហ្នឹងឯង ។

ម៉ៅ ៖ ចាប់ ។

ធានី ៖ ហើយចឹងពុល ធ្វើម៉េចបានជាវិញ?

ម៉ៅ ៖ ពេទ្យគេមិនដឹងគេចាក់អីដល់អីទេ គេឲ្យថ្នាំអីទេ មិនដឹងគេឲ្យថ្នាំ ។

ធានី ៖ ដាក់ទៅគេព្យាបាលប៉ុន្មានថ្ងៃបានជា?

ម៉ៅ ៖ មិនដឹងជា ប្អូនអើយវាភគអាចម៍វាទាំងអស់គ្នា វាគ្មានអ្នកណាខ្វាស់អ្នកណាទេ ភគពេកព្រៃ មុនដំបូងរត់ ក្រោយដេកហៀរយកតែមុង ។ ដល់រួចបានឃើញពេទ្យកងទ័ពគេទៅជួយ ខ្ញុំនឹងក៏មិនដឹងថាខ្លួនឯងគេដឹកយកទៅណាទៅណែដែរហ្នឹង ។

ធានី ៖ មានដឹកដល់ភ្នំពេញទេ?

ម៉ៅ ៖ ដឹងដល់ណាប្អូនអត់ដឹង ស្រាប់តែឃើញនៅមន្ទីរពេទ្យ ។

ធានី ៖ មន្ទីរពេទ្យនៅណាដឹងទេ គេហៅមន្ទីរពេទ្យអី?

ម៉ៅ ៖ អឺ ពុលថ្នស ឃើញគេថាពេទ្យអន្តការអើ ។

ធានី ៖ ពេទ្យ១៧មេសា?

ម៉ៅ ៖ ពេទ្យនៅបន្ទាយឆ្ងាយ ប៉ុន្តែមិនដឹងគេហៅស្អី ។

ធានី ៖ ពេទ្យបន្ទាយឆ្ងាយនៅណាវិញ?

ម៉ៅ ៖ បន្ទាយឆ្ងាយនៅស្រុកកោះអណ្តែត ។

ធានី ៖ អឺ! នៅកោះអណ្តែត?

ម៉ៅ ៖ ចាំ! នៅស្រុកកោះអណ្តែត ។

ធានី ៖ ទៅពេទ្យនៅហ្នឹងអត់បានមកភ្នំពេញ?

ម៉ៅ ៖ អត់បានមកភ្នំពេញទេ គេមិនបញ្ជូនយើងទេ ប្អូនស្លាប់១ទៅ រស់១ទៅ ។

ធានី ៖ ស្លាប់ច្រើនទេ មីងកាលពេលពុលហ្នឹង?

ម៉ៅ ៖ អត់មានស្លាប់ទេ គ្រាន់ថាវាប្រើការមិនកើត ដូចថានិយាយដើងទៅលិច និយាយលិចទៅឯត្បូងទៅ ។

ធានី ៖ ចា៎! ហើយដល់ពេលមីងថាពុល គេចាប់បានហេតុអីបានគេដាក់ថ្នាំពុលនៅក្នុងឡកងចល័ត?

ម៉ៅ ៖ ចុះយើងវាមិនដឹងដែរ យើងដឹងថាហូប ដល់ហូបទៅវាភគវារុះចឹង ដល់នេះផ្នែកតាម៉ុកហ្នឹងគាត់តាមដានគាត់ចាប់ តាម៉ុកគាត់ចុះទៅចាប់ផ្ទាល់ ។

ធានី ៖ អូ! គាត់ទៅចាប់ផ្ទាល់?

ម៉ៅ ៖ ចា៎! គាត់ប្រើកូនចៅគាត់ចូលចាប់ ។

ធានី ៖ អ្នកណាគេស្គាល់ទេកូនចៅគាត់?

ម៉ៅ ៖ ខ្ញុំមិនស្គាល់ទេ ខ្ញុំឮតែគេថាទេ ព្រោះអីខ្ញុំនៅគុម្ពបេកហើយ ។

ធានី ៖ ភគហើយរកទៅណាមិនរួចទេ?

ម៉ៅ ៖ ចា៎! ខ្ញុំនៅគុម្ពបេក ។

ធានី ៖ ចុះយាយបូអីមានចុះមកមើល មកសួរសុខទុក្ខ?

ម៉ៅ ៖ ទេ! យាយបូគាត់កាន់ស្រុកតើ ស្រុក១០៩ ។

ធានី ៖ ស្រុក១០៩ អត់មានពាក់ព័ន្ធហ្នឹងនេះទេ?

ម៉ៅ ៖ អត់ពាក់ព័ន្ធទេ ។

ធានី ៖ ដល់ចឹង ចល័តតំបន់១៣ហ្នឹង អ្នកណាគេអ្នកក្តាប់នៅហ្នឹង ដឹងមីងទេ?

ម៉ៅ ៖ យាយនួន យាយខនហ្នឹងឯងគេក្តាប់ ។

ធានី ៖ យាយនួន យាយខន?

ម៉ៅ ៖ ហ្នឹង អាហ្នឹងគេមេលើ មេក្តាប់រួមម៉ង ។

ធានី ៖ ចឹងយាយនួន យាយខនហ្នឹង ជាមេ?

ម៉ៅ ៖ មេកាន់តំបន់ម៉ង មេតំបន់ ។

ធានី ៖ មេកងតំបន់១៣ចឹង មីង?

ម៉ៅ ៖ ចា៎!

ធានី ៖ ដំបូងស្មានតែគាត់ជាត្រឹមមេកងតូចតាច តាមពិតមេកងតំបន់១៣?

ម៉ៅ ៖ តំបន់១៣ ។

ធានី ៖ យាយនួន យាយខន តើមីងដឹងថាគាត់ធ្វើអីពីមុនមក ដូចគាត់មានដូចថាបងប្អូនជាប់សាច់ញាតិអីទេ? អត់ដឹងៗគាត់មកពីណា?

ម៉ៅ ៖ ទេ! នៅស្រុក១០៥ ស្រុកនោះគេហៅស្រុកត្រាំកក់ គេហៅ១០៥ ។

ធានី ៖ ចឹងយាយនួន យាយខនហ្នឹង អ្នកនៅស្រុក១០៥?

ម៉ៅ ៖ ចា៎!

ធានី ៖ គាត់កាចអត់មីង?

ម៉ៅ ៖ យើងនៅរយាលឆ្ងាយចឹង យើងមិនដឹងទេ ព្រោះអីគេធ្វើការៗទៅ គេដើរលើកខ្នងប្រឡាយហើយៗគេហើយ គេមានទៅធ្វើអីយើង ។

ធានី ៖ ឲ្យតែខំប្រឹងធ្វើការ?

ម៉ៅ ៖ ហ្នឹងហើយ ។

ធានី ៖ ហើយចុះពេលដែលមីងនៅលើកនៅអីចឹង អឺ!មានអ្នកខ្លះធ្វើអត់បានចឹងយ៉ាងម៉េចទៅ?

ម៉ៅ ៖ បើធ្វើអត់បាន យើងស្រណោះគ្នាយើងជួយ កុំឲ្យគេដឹង ។

ធានី ៖ អូ! យើងជួយដែរ?

ម៉ៅ ៖ ចា៎!

ធានី ៖ ចុះមីងមានជួយគេជួយអីដែរ?

ម៉ៅ ៖ ជួយគ្នាទៅវិញទៅមក ជួនកាលខ្ញុំលើកហើយមុនគេទៅ ជួនកាលគេលើកហើយមុនខ្ញុំទៅ ។

ធានី ៖ ជួយគ្នាទៅវិញទៅមក ក្នុងកងល្អដែរ ។

ម៉ៅ ៖ ប៉ុន្តែគេនៅអត់ជួយទេ ។

ធានី ៖ ម៉េចចឹងមីង?

ម៉ៅ ៖ គេនៅគេដាក់ពិន័យអ្នកជួយទៀត គេថែមដីឲ្យយើងទៀត ។

ធានី ៖ ចឹងទៀត?

ម៉ៅ ៖ ចា៎!

ធានី ៖ ចឹងយើងធ្វើប៉ុន្មាន ឧទាហរណ៍ថាម៉ាកង១០នាក់ចឹង យើងអត់ជួយគ្នាបានទេ?

ម៉ៅ ៖ យើងជួយបានមេក្រុមយើង

កងតូចៗកងហាយើងក្នុងម៉ាកងហាយើងជួយគ្នាបានប៉ុន្តែជួយជា សំងាត់កុំឲ្យកងរយគេដឹង ។

ធានី ៖ ចឹងទៀត តែគេដឹងគេដាក់ទោសយើងវិញ?

ម៉ៅ ៖ តែគេដឹងគេកិនកងហាហ្នឹង កងហាកិនមេក្រុម ។

ធានី ៖ ធ្ងន់យើងបណ្ដោយ?

ម៉ៅ ៖ ចាំ!

ធានី ៖ តែធ្លាប់មានទេ មានជួយគេហើយ ត្រូវគេដាក់ទោសទេ?

ម៉ៅ ៖ មានតើ ។

ធានី ៖ អ្នកផ្សេងអី?

ម៉ៅ ៖ មាន ។

ធានី ៖ មីងមានដែរ?

ម៉ៅ ៖ ខ្ញុំមិនដែលបានទេ ។

ធានី ៖ ដល់យើញគេដាក់ទោសចឹងម៉េចទៅ?

ម៉ៅ ៖ យើញគេ យើង ។

ធានី ៖ ខ្លាចដែរ?

ម៉ៅ ៖ យើងខ្លាចដែរ ។

ធានី ៖ លែងហ៊ានជួយគេ?

ម៉ៅ ៖ លែងហ៊ានជួយគេ ។

ធានី ៖ ជួយគេវេទនា?

ម៉ៅ ៖ ប៉ុន្តែយើងប្រុងជួយគេចឹង យើងធ្វើដូចខុបមាថាជិតហើយចឹងយើងធ្វើតិចៗទៅណា ។

ធានី ៖ ចាំគេ?

ម៉ៅ ៖ យើងធ្វើមើលតើដូចថាបងដល់ត្រឹមនេះហើយ យើងដូចថាហត់ចឹង យើងដូរគ្នាឲ្យអាគ្នាហត់ មកកាប់ដីឡូត៍យើង យើងទៅយកអាដីឡូត៍នោះវិញ សាមញ្ញក្នុងហ្នឹង ។

ធានី ៖ អូ! មីងចេះជួយចឹងនោះ?

ម៉ៅ ៖ ចាំ!

ធានី ៖ ចាំឈ្មោះគាត់ទេ មីងជួយហ្នឹង?

ម៉ៅ ៖ ជួយអាតូចអាអីហ្នឹង ប៉ុនឥឡូវនេះយកប្តីពិការនេះ ដល់ណាដល់ណែអស់ហើយហ្នឹងបែកគ្នា ។

ធានី ៖ អាតូចហ្នឹងមកពីណាវិញ?

ម៉ៅ ៖ ចាំ! វានៅស្រុក១០៥នេះឯង ។

ធានី ៖ ឈ្មោះតូចស្រី ហើយប្រុស?

ម៉ៅ ៖ ស្រី សំណាប់អ្នកណាគេដាក់ប្រុសមួយ ។

ធានី ៖ ១០៥ ដឹងរាល់ថ្ងៃ គាត់នៅរស់ ឬស្លាប់ទេ?

ម៉ៅ ៖ អត់ដឹងដែរ គេយកប្ដីវាពិការទាំងពីរ អាហ្នឹងសុទ្ធតែយកប្ដីសិនដូចតែគ្នា គេថាយកពិការ ។

ធានី ៖ ចឹងមីងរៀបគ្រួសារឆ្នាំប៉ុន្មាន?

ម៉ៅ ៖ ចាំ! ខ្ញុំឆ្នាំប៉ុន្មានទេ ៧៩ ហើយហ្នឹង ។

ធានី ៖ ពេលមីងធ្វើទាហានហើយ?

ម៉ៅ ៖ ចាំ! ចាប់ដៃ ខ្ញុំចាប់ដៃ ។

ធានី ៖ ចឹងពេលមីងចូលធ្វើទាហានហើយ?

ម៉ៅ ៖ ចាំ!

ធានី ៖ ចូលធ្វើទាហានហើយបានចាប់ផ្ដើមការ?

ម៉ៅ ៖ ចាំ!

ធានី ៖ ចឹង៧៩ ហើយបានការ?

ម៉ៅ ៖ ចាំ! ខ្ញុំចុងហើយ ។

ធានី ៖ ការនៅណាវិញ ការនៅក្នុងសម័យហ្នឹងវិញ?

ម៉ៅ ៖ សម័យហ្នឹងដែរ ប៉ុនខ្ញុំមកព្រំដែន ។

ធានី ៖ អូ! រត់មកព្រំដែន ហើយបានការ?

ម៉ៅ ៖ ចាំ!

ធានី ៖ នៅការនៅណាវិញ?

ម៉ៅ ៖ ខ្ញុំចាប់ដៃគ្នានៅបឹងត្រកួននេះ ។

ធានី ៖ អូ! នៅក្បែរយើងនេះ?

ម៉ៅ ៖ ចាំ!

ធានី ៖ ឆ្នាំ១៩៧៩មីងនោះ?

ម៉ៅ ៖ ចាំ!

ធានី ៖ គ្រួសារមីងឈ្មោះអីគេ?

ម៉ៅ ៖ តាខ្ញុំហ្នឹងតាអុល ។

ធានី ៖ អីគេអុល?

ម៉ៅ ៖ ចាំមើលឈ្មោះក្នុងសៀវភៅគ្រួសារអ៊ុក ប៉ុនឈ្មោះទាហាន ដួង ដាក់ដួង ។

ធានី ៖ អីគេអ៊ុក?

ម៉ៅ ៖ អឺ!ឈ្មោះក្នុងសៀវភៅគ្រួសារ អ៊ុក សំអុល ប៉ុនតែដល់ក្នុងគាត់ធ្វើទាហានគេដាក់មិនស្គាល់ឈ្មោះគាត់គេដាក់អ៊ុកទៅ យកអ៊ុកហ្នឹងរហូតទៅ អឺ! ដួង ។

ធានី ៖ ចឹងដួងសំអុល?

ម៉ៅ ៖ ចា៎!

ធានី ៖ និយាយទៅគាត់ឈ្មោះអុលដដែល គ្រាន់សំតែដូរតែត្រកូលទេ ធ្វើទាហានគាត់ដាក់ដួងសំអុលអីចឹងទៅ ។ ចឹងពេលធ្វើទាហានជាមួយមីងៗស្គាល់តែដួងសំអុលទេ?

ម៉ៅ ៖ ទេ! ខ្ញុំមិនដែលស្គាល់ទេ ។

ធានី ៖ ហា៎! ចុះពេលមីងរៀបការ?

ម៉ៅ ៖ ដល់រៀបការហើយបានស្គាល់ ។

ធានី ៖ ហា៎! កាលពេលមុនហ្នឹងក៏អត់ស្គាល់ដែរ?

ម៉ៅ ៖ ទេ!

ធានី ៖ ចុះម៉េចបានគេឲ្យនៅជាមួយគ្នា?

ម៉ៅ ៖ យើងចេះរត់ត្រឡប់ត្រឡិនគ្នា កងដូចថាវៃ ហា៎!វៃស្វាយចេក ហា៎!វៃបឹងត្រកួន ដល់យើងរត់ឡើង យើងរត់យើងមិនទៅភ្នំដី យើងមិនឡើងទៅទាំងអស់គ្នា ទៅរៀបកម្លាំងនៅហ្នឹង ។

ធានី ៖ ដល់ពេលរៀបនៅហ្នឹង អ្នកណាគេអ្នករៀបការឲ្យមីង?

ម៉ៅ ៖ ចា៎! ខ្ញុំអឺ!ភ្លេចមេរៀបឲ្យទៀត តារៀម ។

ធានី ៖ តារៀម?

ម៉ៅ ៖ ចា៎!

ធានី ៖ អីគេ តារៀមហ្នឹងគាត់ធ្វើអីគេ បានមករៀបឲ្យមីងចឹង?

ម៉ៅ ៖ ចា៎! គាត់កាន់កងទ័ពដែរ ។

ធានី ៖ កងទ័ពៗនារី កងទ័ពបុរស?

ម៉ៅ ៖ បុរស ។

ធានី ៖ កងទ័ពបុរស?

ម៉ៅ ៖ ចា៎!

ធានី ៖ ខាងណាវិញ កងទ័ពបុរសហ្នឹង?

ម៉ៅ ៖ ខ្មែរក្រហម ។

ធានី : យល់ហើយដូចថាប្រធានមួយណា ប្រធានរបស់តារៀមហ្នឹង?

ម៉ៅ : តានោះ តារឿន ។

ធានី : តារឿន?

ម៉ៅ : ចា៎!

ធានី : អូ! តារឿនប្រធានរបស់គាត់?

ម៉ៅ : ចា៎! តារឿន ហើយតានេះស្អីទេ កងពលតាអីគេ ។

ធានី : ចឹងតារឿនគាត់មក?

ម៉ៅ : មក ។

ធានី : ស្រួលដែល មិញខ្ញុំថារកចង់ជួបគាត់ ចឹងតារឿនគាត់មេរបស់តារៀមហ្នឹង?

ម៉ៅ : មិនមែនទេ មួយទៀត តាអីទេ តាយាំ អឺ!តាអីទេ ខ្ញុំមិនចាំអាមេហ្នឹង មេមិញៗ ។

ធានី : តាសារឿន?

ម៉ៅ : តាសារឿនហ្នឹង ។

ធានី : ប្រធានធំ?

ម៉ៅ : ហ្នឹងហើយ និយាយទៅដាក់តារៀមបានហើយ ខាងលើគាត់ខ្ញុំមិនស្គាល់ ។

ធានី : អត់ច្បាស់?

ម៉ៅ : ចា៎!

ធានី : ភ្លេច មិនមែនមិនស្គាល់ទេ?

ម៉ៅ : ស្គាល់ នៅជាមួយគ្នាហ្នឹង ប៉ុនខ្ញុំរាយរាប់វាមិនអស់ ។

ធានី : ចឹងតារៀមហ្នឹងអ្នករៀបចំឲ្យមីងមានគ្រួសារ តែម្នាក់ឯងទេ ម៉ាគូមីងទេ?

ម៉ៅ : ចា៎!

ធានី : តារៀមជាកងទ័ព ជាអ្នករៀបចំ?

ម៉ៅ : ហ្នឹងហើយ ។

ធានី : ការពេលរៀបគ្រួសារហ្នឹងគេរៀបម៉េច?

ម៉ៅ : ចាប់ដៃ ។

ធានី : ចាប់ដៃគ្នា?

ម៉ៅ : ចា៎!

ធានី : តែប៉ុនហ្នឹង អត់មាននិយាយអីអត់?

ម៉ៅ ៖ ឲ្យប្ដេជ្ញាឲ្យថែគ្នាទៅវិញទៅមក ។

ធានី ៖ អូ! និយាយចឹង?

ម៉ៅ ៖ ចាំ!

ធានី ៖ ហើយកាលពេលមីងរៀនគ្រួសារហ្នឹងមានឪពុកម្ដាយខាងយើងខាងអីមកទេ?

ម៉ៅ ៖ អត់ទេ យើងអត់កំពុងតែនេះ ម៉េចត្រូវគ្នា ។

ធានី ៖ កាល៧៩ហ្នឹងៗមីងរត់មកដល់បឹងត្រកួនហើយ?

ម៉ៅ ៖ ចាំ!

ធានី ៖ បឹងត្រកួននៅព្រំដែន?

ម៉ៅ ៖ នេះបឹងត្រកួនយើងព្រំដែននេះ ។

ធានី ៖ អាហ្នឹងគេហៅភូមិឃុំអីគេ?

ម៉ៅ ៖ អាហ្នឹងយើងរត់មកហ្នឹងវិញហើយ
អាហ្នឹងកន្ទែពដែលយើងប្រជុំជួរចែកដែនការគ្នាដូចកន្ទងឯង ទៅនៅស្វាយចេកទៅ កន្ទខ្ញុំនៅភ្នំស្រុកទៅ អាហ្នឹងចេះចែកគ្នា ។

ធានី ៖ ចឹងមើលចង់ឲ្យមីងពិពណ៌នាតិចមើល កាលជំបូងមីងរត់ មីងមិននៅកន្ទែពខាងតាកែវ ម៉េចបានមីងមកដល់ខាងនេះ?

ម៉ៅ ៖ ចុះពួកយួនដេញ យើង៧៩ ។

ធានី ៖ យួនដេញៗមីងរត់ទៅណាខ្លះ?

ម៉ៅ ៖ ខ្ញុំរត់មិនឆ្ងាយទេ ខ្ញុំរត់បានត្រឹមរត់ពីកងចល័តមក ខ្ញុំរត់មកៗ៧៧គេរើមកៗខ្ញុំរត់គេដឹករទេះភ្លើងនៅយើងភ្នំស្រុកស្វាយនេះ ។

ធានី ៖ ចុះមីងថាមីងរៀបគ្រួសារហ្នឹង គេឲ្យរៀបហ្នឹងគឺក្រោយ៧៩ចឹង អេ!ពេល៧៩?

ម៉ៅ ៖ ៧៩ ប៉ុនចុងចូល៨០ហើយណា៎ ។

ធានី ៖ ចុះមីងថាមីងធ្វើទាហាននោះ?

ម៉ៅ ៖ ធ្វើទាហានខ្ញុំនៅលីវ ។

ធានី ៖ ហ្នឹងហើយធ្វើទាហានហ្នឹង ដែលមីងថាពិបាកពេកឃើញគេរើអត់អីហូបក៏ឈប់ធ្វើទាហាននៅផ្ទះបានហូប ។ អាហ្នឹងពេល៨០ហើយ?

ម៉ៅ ៖ នៅតាម ហ្នឹងហើយ ។

ធានី ៖ ចង់សួរមីងថាមីងមិញថាមីងធ្វើទាហាននៅឆ្នាំ៧៧ចឹង?

ម៉ៅ : ចា៎!

ធានី : ចឹងធ្វើទាហាន៧៧ ធ្វើទាហានវ៉ៃនៅណា?

ម៉ៅ : ខ្ញុំមិនបានវ៉ៃទេ គ្រាន់តែជញ្ជូនឲ្យគេ ។

ធានី : ហ្នឹងហើយ លើកជញ្ជូនគ្រាប់ជញ្ជូនអីនៅណាចេះ?

ម៉ៅ : អឺ! ជញ្ជូន ណា៎ទេតា ។

ធានី : នៅតាកែវយើង ឬក៏នៅ?

ម៉ៅ : អត់នៅតាកែវ ។

ធានី : អឺ! នៅកំពង់ឆ្នាំង មីងថានៅកំពង់ឆ្នាំង?

ម៉ៅ : អឺ!

ធានី : ជញ្ជូនគ្រាប់នៅកំពង់ឆ្នាំង ហើយបន្ទាប់មកទៀតមីងជិះរទេះភ្លើងឡើងមកនេះម៉ងទៅ ឡើងមកភ្នំស្រុក?

ម៉ៅ : ចា៎!

ធានី : ទៅកំពង់ឆ្នាំង ទៅភ្នំស្រុក ចឹងរត់ពីតាកែវទៅកំពង់ឆ្នាំងសិន?

ម៉ៅ : ចាំមើល ។

ធានី : កាលហ្នឹងវៀតណាមវ៉ៃហើយ?

ម៉ៅ : វ៉ៃហើយ ចូលវ៉ៃ ។

ធានី : វ៉ៃហើយបានមីងរត់ពីតាកែវទៅកំពង់ឆ្នាំង ហើយបានជញ្ជូនគ្រាប់សិន?

ម៉ៅ : ចាំមើលប្អូនខ្ញុំនិយាយ

ចាំមើលខ្ញុំចេញពីមុនដំបូងយើងធ្វើកងចល័តតំបន់ៗ ហើយចូលមកកំពង់ ឆ្នាំងបានតែ២-៣ថ្ងៃទេៗ ឡើងមកនេះជិតបវេលហ្នឹងគេបញ្ជូនមកនៅពាយ័ព្យនេះៗ បាន ជិតម៉ាឆ្នាំបានយួនវ៉ៃ ។ យួនវ៉ៃៗអាហ្នឹងចូលជញ្ជូនពេញធីងហើយជញ្ជូនគ្រាប់ឲ្យគេ វាត្រឡប់

ត្រឡិន ។

ធានី : យួនវ៉ៃហើយបានជញ្ជូនគ្រាប់ៗ ហើយរត់ពីតាកែវមកកំពង់ឆ្នាំង?

ម៉ៅ : ចា៎! រត់ពីកំពង់ឆ្នាំងមកបានគេដឹកមកឡើងជិះរទេះភ្លើងឡើងមកនេះ ។

ធានី : ឡើងជិះរទេះភ្លើងទៅដល់ ។

ម៉ៅ : មកនៅភូមិភាគពាយ័ព្យនេះណា ។

ធានី :	ដល់ភូមិភាគពាយ័ព្យ ទៅបាត់ដំបង ឬក៏ទៅភ្នំស្រុកម៉ង មកនៅភ្នំស្រុក?

ម៉ៅ :	មកនៅភ្នំស្រុក ឡើងភ្នំស្រុក ។

ធានី :	ភ្នំស្រុកទៅដើរទៅ?

ម៉ៅ :	ចា៎! ចូលភ្នំកូនខ្មែរកូនអី រៀបរាប់មិនអស់ទេ បើប្អូនឯងសរសេរច្រើនណាស់ ។

ធានី :	ចឹងមីងរហូតមកដល់ចឹងត្រកូលយើងនេះ ។ ចឹងពេលណាគេចងក្រងជាអង្គភាពជាអី?

ម៉ៅ :	វាមានអង្គភាពគេមកតាំងចឹងមករហូត ។

ធានី :	ចឹងពេលមីងមកដល់ហ្នឹង មានអង្គភាពហើយ?

ម៉ៅ :	ចា៎! ដូចថាមកចឹងថាប្អូនឯងដាច់កងដាច់ក្រុមចឹង ស្គាល់គ្នាចូលតាមគ្នាចឹងណាប្អូន ។

ធានី :	ចឹងអ្នកណាអ្នកចងក្រងជាអង្គភាព ជាក្រុមហ្នឹង ដែលដូចថាយើងធម្មតាអ្នកមកមុនចូលមុន អ្នកមកក្រោយចូលកងក្រោយចឹង?

ម៉ៅ :	ដូចថាខ្ញុំចូលតាមគេចឹងប្អូនអើយ វាមិនដឹងអ្នកណាមេកងអ្នកណាមេក្រុម ចេះតែចូលតាមៗគេ ដូចថានៅជាមួយប្អូនស្រួលចឹងឯងចេញពីកងហ្នឹងមកនៅជាមួយអញវាស្រួលចេះណា ។

ធានី :	អូ! រត់មកតាមគេទៅ?

ម៉ៅ :	វាចឹងណា ។

ធានី :	ហើយកាលហ្នឹងម៉េចបានមីងជ្រើសរើសយកកងនៅខាងនេះ?

ម៉ៅ :	អឺ! គេថានិយាយទៅគេថាកងខាងនេះមិនសូវវៃ មិនសូវឡើងវៃញឹកញាប់ទៅ ។ ហើយដល់នេះយើងលួចរត់មកទៅតាមគេតាមឯងទៅ ។

ធានី :	កាលហ្នឹងមីងរត់ពីណាមក បានមកដល់នេះ?

ម៉ៅ :	អឺ! ចេញកងវាមិនឆ្ងាយពីគ្នាទេ ប្អូន គ្រាន់ផ្លាស់កងដូចថាឯងកងយាយបូចឹង ខ្ញុំមកកងយាយយ៉ុនចឹងទៅ គ្រាន់តែដូរក្រុម ។

ធានី :	ចឹងមីងកាលហ្នឹងរត់មកកងពីណា រត់មកគេមក?

ម៉ៅ :	មិនអីទេប្អូន គ្រាន់តែកង ជុះនៅជិតគ្នាចឹង គ្រាន់ប្តូរកងគ្នាតើ យើងឃើញមុខគ្នារាល់ថ្ងៃទេ ។

ធានី :	ហើយបន្ទាប់មកទៀត ចឹងពេលមីងរៀបគ្រួសារមីងនៅផ្ទុះឈប់ធ្វើទាហានហើយ?

ម៉ៅ :	ខ្ញុំឈប់ហើយ ប៉ុន្តែមិនធ្វើទាហានក៏ដូចជាធ្វើទាហាន មានប្តីក៏ដូតែអត់ប្តី ។

ធានី :	ម៉េចចឹងមីង?

ម៉ៅ :	យើងកូនកើតតែឯងអីតែចឹងទៅ ។

ធានី :	កើតកូនឆ្នាំប៉ុន្មាន កើតកូនបងគេ?

ម៉ៅ ៖ កូនខ្ញុំកើតឆ្នាំ៨២ ។

ធានី ៖ អូ! ពេលសង្គ្រាម ចឹងពេលហ្នឹងមីងលែងឡើងទៅវៃ មីងនៅបឹងត្រកួនហ្នឹងវិញ ឬក៏នៅជំរំ?

ម៉ៅ ៖ នៅបឹងត្រកួនក៏រត់ដូចតែគ្នា ។

ធានី ៖ ចុះមីងទៅនៅជំរំពេលណាដែរ?

ម៉ៅ ៖ ទៅនៅជំរំឆ្នាំប៉ុន្មានទេ ខ្ញុំមិនដឹងទេ ៨៤ ។

ធានី ៖ ៨៤ ចឹងបានកូន២ឆ្នាំហើយ?

ម៉ៅ ៖ ចា៎!

ធានី ៖ ហើយទៅនៅជំរំបានប៉ុន្មានឆ្នាំ បានត្រឡប់មកយើងវិញ?

ម៉ៅ ៖ ខ្ញុំទៅនៅជំរំបានកន្លះឆ្នាំ ខ្ញុំមកតាមខ្មែរក្រហមវិញ ។

ធានី ៖ ទៅនៅណាទៅវិញទៅ មកតាមខ្មែរក្រហម?

ម៉ៅ ៖ ចា៎! ខ្ញុំនៅជប់គគីរវិញ ។

ធានី ៖ អូ! នៅជប់គគីរ?

ម៉ៅ ៖ គេដឹកដាក់៨៥ គេថាជំរំ៨៥ក្នុងដីថៃ ។

ធានី ៖ តែមីងអត់ទៅ?

ម៉ៅ ៖ ទៅតែទៅតាមគេហ្នឹង ។

ធានី ៖ អូ! ជប់គគីរហ្នឹងគេថា៨៥?

ម៉ៅ ៖ ទេ! ប្អូន៨៥ផ្សេង ជប់គគីរផ្សេង ។

ធានី ៖ តែដំបូងមីងនៅជប់គគីរ ឬនៅជំរំ៨៥?

ម៉ៅ ៖ នៅ៨៥សិន ចេញពីជំរំតាង៉ុកមកគេហៅជំរំសាយអេចនោះ ។

ធានី ៖ ចឹងដំបូងតាង៉ុកសិន?

ម៉ៅ ៖ ចេញពីហ្នឹងហើយចេញពីតាង៉ុកមក បានមក៨៥ ។

ធានី ៖ សាយអេច ចឹងជំរំតាង៉ុកហ្នឹងហៅជំរំសាយអេច?

ម៉ៅ ៖ ចា៎ៗ ។

ធានី ៖ ជំរំតាង៉ុកហើយបានទៅ៨៥ ៗហើយបានទៅជប់គគីរ?

ម៉ៅ ៖ ចាំមើលរាប់ត្រឡប់ត្រឡិនចេះ ប្អូនឯងមិនទាន់កាល់ ចាំមើលណាមុនដំបូងខ្ញុំចាប់គ្រួសារនៅបឹងត្រកួន ។

ធានី ៖ បីងត្រកួនហ្នឹងហើយ?

ម៉ៅ ៖ ដល់វៃបីងត្រកួនបាត់រត់ទៅនៅម៉ាឡៃ ។

ធានី ៖ ទៅម៉ាឡៃ អូ១!មីងទៅនៅម៉ាឡៃដែរ?

ម៉ៅ ៖ ហ្នឹងហើយ ដល់គេវៃម៉ាឡៃបែករត់ចូលតាឆ្មុំក ដល់គេនៅជំរំតាឆ្មុំក គេស៊ីអង្ករ គេឲ្យតែកូនស្រីខ្ញុំកូនប្រុសខ្ញុំមកតាមខ្មែរក្រហមវិញ មកនៅ៨៥ ។

ធានី ៖ ៨៥ បន្ទាប់មកទៀតបាននៅជប់គគីរ?

ម៉ៅ ៖ ចា៎! ចេញពីជប់គគីរមកនៅមេបុណ្យ ។

ធានី ៖ មេបុណ្យហើយទៅណាទៀតទៅ?

ម៉ៅ ៖ ចេញពីមេបុណ្យមក ខ្ញុំទៅនៅស្តោ ដល់ពេលគេវៃបែកស្តោមកនៅនេះវិញ ។

ធានី ៖ មកនៅ?

ម៉ៅ ៖ នៅហ្នឹង ។

ធានី ៖ បន្ទាយឆ្មារហ្នឹង?

ម៉ៅ ៖ ចា៎!

ធានី ៖ ចឹងមីងនៅបីងត្រកួនបានប៉ុន្មានឆ្នាំ បានទៅម៉ាឡៃ?

ម៉ៅ ៖ យើង៧៩រហូត ។

ធានី ៖ ប៉ុន្មានខែអីមីងចាំទេ?

ម៉ៅ ៖ ច្រើនឆ្នាំដែរ ។

ធានី ៖ មើលបីងត្រកួន៧៩រហូត បីងត្រកួន១៩៧៩ ដល់ពេលនៅម៉ាឡៃឆ្នាំប៉ុន្មាន?

ម៉ៅ ៖ មិនដឹងឆ្នាំប៉ុន្មានទេ មិនគិតមិនគូរផង ។

ធានី ៖ ព្រោះមីងថាកាលហ្នឹង៨៤ ទៅជំរំ?

ម៉ៅ ៖ ហ្នឹងហើយ ។

ធានី ៖ ជំរំសាយធូ បីងត្រកួននៅជំរំសាយធូ?

ម៉ៅ ៖ ទេ! អត់ទេ ។

ធានី ៖ ចុះមីងថានៅសាយធូដែរ?

ម៉ៅ ៖ អត់នៅសាយធូទេ ខ្ញុំនៅសាយអេច ។

ធានី ៖ អត់មានសាយធូទេ?

ម៉ៅ ៖ អត់មានសាយធូទេ ខ្ញុំនៅសាយអេចគេហៅតាឆ្មុំក ។

ធានី ៖ ចឹងមីងនៅបឹងត្រកួនហើយរត់ទៅម៉ាឡៃ?

ម៉ៅ ៖ ចា៎!

ធានី ៖ ទៅម៉ាឡៃ កាលហ្នឹង៨៤ឥឡូវ ៨៤ ៨៥?

ម៉ៅ ៖ ៨៤ចឹង ។

ធានី ៖ ៨៤ ពេលដែលមីងបានកូន២ ១៩៨៤នៅម៉ាឡៃ ។ បន្ទាប់មកនៅតាង៉ុកនៅឆ្នាំប៉ុន្មាន?

ម៉ៅ ៖ ៨៤ហ្នឹងឯង អាមួយដើម អាមួយចុងហ្នឹងឯង ។

ធានី ៖ អូ! ចឹងអានេះចុង?

ម៉ៅ ៖ ហ្នឹងហើយ ចុង៨៤ខ្ញុំនៅអឺ!តាង៉ុក ។

ធានី ៖ ហើយដល់ពេលហើយ៨៥ ឆ្នាំប៉ុន្មាន៨៥ដែរ?

ម៉ៅ ៖ ៨៥ កូនខ្ញុំកើតហ្នឹងជំរំ៨៥ ខ្មែរក្រហមគេដឹកដាក់ព្រំដែនថៃ នៅក្នុងដីថៃ ។

ធានី ៖ អានេះឆ្នាំប៉ុន្មាន?

ម៉ៅ ៖ ៨៥ហ្នឹងម៉ង ។

ធានី ៖ ១៩៨៥?

ម៉ៅ ៖ ហ្នឹងហើយ ។

ធានី ៖ បន្ទាប់មកទៀតទៅជប់គីរឆ្នាំប៉ុន្មានទៅ?

ម៉ៅ ៖ ដឹង៨០ប៉ុន្មានទេ ៨៩ ។

ធានី ៖ ៨៩?

ម៉ៅ ៖ ឈប់ៗ តាយើងមកនៅនេះ៨០ប៉ុន្មានតា យើងមកនៅអឺ!នេះនៅមេបុណ្យនេះ៨០ប៉ុន្មាន អឺ!នៅជប់គគីរ ៩០ប៉ុន្មាន អឺ!៨៩ ។

ធានី ៖ ចុះទៅមេបុណ្យ?

ម៉ៅ ៖ មេបុណ្យ ៩១ មិនដឹងប៉ុន្មានទេប្អូន ។

ធានី ៖ ចុះនៅស្ពោនោះ?

ម៉ៅ ៖ ស្ពោៗគេដេញទៅខ្ញុំ៩៣ ។

ធានី ៖ ៩៣ ចាំដែលមីង ។ ចុះយើងនៅបន្ទាយឆ្មារយើងនៅឆ្នាំប៉ុន្មាន?

ម៉ៅ ៖ បន្ទាយឆ្មារខ្ញុំនៅ៩១ ។

ធានី ៖ អឺ! ៩១ ៩៦?

ម៉ៅ ៖ ៩១ ។

ធានី : ហា៎!ចឹងមីងថានៅ៩១នៅមេបុណ្យ?

ម៉ៅ : មេបុណ្យ ៩០ប៉ុន្មានៗ

ធានី : ពេលហ្នឹងគេសមាហរណកម្មហើយឬនៅ?

ម៉ៅ : ចា៎! គេសមាហរណកម្មហើយៗ

ធានី : គេចូលហើយ ព្រោះយើងមកនៅនេះហើយៗ ចឹងសមាហរណកម្មឆ្នាំ៩៦ ៩៧?

ម៉ៅ : មិនដឹង៩០ប៉ុន្មានទេ មិនដឹងទេៗ

ធានី : អត់ច្បាស់ទេ អាច៩៦ ឬ៩៧?

ម៉ៅ : ហ្នឹងៗ

ធានី : ចុះមីងមកនៅតាំងពី៩៦ ៩៧?

ម៉ៅ : នេះ ខ្ញុំមកនៅ៩៨ៗ

ធានី : អូ! មកនៅ៩៨?

ម៉ៅ : អឺ!

ធានី : ចឹងត្រូវហើយ ចង់សួរមីងមកនៅហ្នឹង៩០ប៉ុន្មានតើៗ

ម៉ៅ : ប្អូនអើយ សួរថាពុលថ្នាំដូចខ្ញុំនិយាយចឹងឯង ប៉ុនប្ដីខ្ញុំមិនប្រកាន់ៗ

ធានី : ចង់សួរមីងកាលពេលនៅចឹងត្រកួនមីងរៀបគ្រួសារ ដល់ពេលមីងទៅម៉ាឡៃ កាលហ្នឹងមីងឃើញទិដ្ឋភាពនៅម៉ាឡៃយ៉ាងម៉េចដែរ មានមីនមានអីទេ ហើយការរស់នៅ?

ម៉ៅ : ប្អូនអើយវើ ប្ដីខ្ញុំមិនដែលនៅផ្ទះទេ....ៗ

ធានី : ហើយចុះបានអីហូបគ្រប់គ្រាន់ទេ កាកបាទអីគេ?

ម៉ៅ : អត់កាកបាទទេ តាកនខបត្ដម្ភៗ

ធានី : ចឹងមីងនៅជាមួយតាកន?

ម៉ៅ : ចា៎!

ធានី : នៅខាងភ្នំព្រឹក អត់ដឹង?

ម៉ៅ : ខ្ញុំគេហៅម៉ាឡៃៗ

ធានី : គេហៅម៉ាឡៃ តែតាកនអ្នកខបត្ដម្ភ?

ម៉ៅ : ចា៎! តាកន អ្នកខបត្ដម្ភ ខ្ញុំកាលហ្នឹងគេហៅគីឡូ១២មិនដឹងណាទេៗ

ធានី : អូ! ហ្នឹងហើយមីងនៅគីឡូ១២ៗកន្លែងតាកនហើយ តាកនអ្នកគ្រប់គ្រងចឹង?

ម៉ៅ : ចា៎! ចឹងៗ

ធានី : ពិបាកដែរយ៉ាងម៉េចមីងបានរត់ទៅនៅជំរំតាង៉ុក?

ម៉ៅ : ប្រើប្អូនអើយ ប្រើដឹកជញ្ជូនផង ប្រើ ។

ធានី : មីង?

ម៉ៅ : ប្រើប្ដី ខ្ញុំមិនដែលបាននៅផ្ទះពីណា ឈឺជាអីគេអ្នកមើល ប៉ុន្តែយើងវាបានថាប្ដីលើកទឹកចិត្ត ថ្នាំ ។

ធានី : ចឹងពិបាកចិត្តពេក ក៏រត់ទៅជំរំទាំងអស់គ្នាទៅ?

ម៉ៅ : អត់ទេ អាហ្នឹងយួនវ៉ៃតើ ។

ធានី : យួនវ៉ៃបែកបានមីងរត់ បានរត់ទៅជំរំតាង៉ុកហ្នឹង?

ម៉ៅ : ចា៎!

ធានី : តែមីងទេ និងគ្រួសារ?

ម៉ៅ : ទៅទាំងគ្រួសារ ៗខ្ញុំគេឲ្យវ៉ៃទៀត គេឲ្យអត់ឡើងឡានផង គេចាប់មកមុខវិញ ។

ធានី : ប៉ុន្តែគាត់រត់មកវិញ ឬក៏គាត់នៅវ៉ៃទៀត?

ម៉ៅ : គាត់រត់មក ដល់នេះគាត់ឡើងឡានមកអន្តភាពវិញ ដែលធ្លាប់យើងនេះគេហៅ៥១៩ ។ យើងដូចថាមាន់គេហៅក្រៅសែរៀនម៉េចទេណា យើងនៅកងខុសគ្នានគ្នា ដូចនៅវាមិនស៊ីចង្វារគ្នា ។

ធានី : អូ! ចឹងគាត់រត់មក៥១៩?

ម៉ៅ : ចា៎! ដល់គាត់រត់មក៥១៩ ខ្ញុំគ្រួសារនេះ សុំតាមអន្តភាពគេសុំយកមកវិញ មកនៅ៨៥ ៨០អីហ្នឹងទៅណាប្អូន ។

ធានី : ចឹង៥១៩នៅជប់គគីរហ្នឹងមែន?

ម៉ៅ : ចា៎!

ធានី : ជប់គគីរ ឥឡូវភូមិហ្នឹងនៅកន្លែងណាមីងដឹងទេ?

ម៉ៅ : ភូមិគេនៅតើប្អូន ។

ធានី : ភូមិហ្នឹងនៅកន្លែង ភូមិជប់គគីរ?

ម៉ៅ : មិនដឹងដែរ បើខ្ញុំលែងទៅហើយ ។

ធានី : អត់ទេ ចង់និយាយថានៅស្រុកយើងនេះ?

ម៉ៅ : អត់ទេ នៅខេត្តខត្តរ ។

ធានី : ខត្តរមានជ័យ?

ម៉ៅ ៖ ចា៎!

ធានី ៖ នៅក្នុងស្រុកអី ស្រុកសំរោងចុងកាល់?

ម៉ៅ ៖ ស្រុកអំពិល ។

ធានី ៖ ស្រុកអំពិល?

ម៉ៅ ៖ ចា៎! ប៉ុនមិនដឹងឃុំអីទេ ។

ធានី ៖ ហើយឃុំជប់គគីរដែរ?

ម៉ៅ ៖ មិនដឹងឃុំអីទេ ។

ធានី ៖ ចឹងកាលហ្នឹងមីងខស្សាហ៍ទៅជប់គគីរដែរ?

ម៉ៅ ៖ អត់ទេ ខ្ញុំនៅហ្នឹងគេឲ្យចុះមក ចុះរហូត មិនដែលចុះឡើងទេ ។

ធានី ៖ ចឹងមីងនៅជប់គគីរៗអត់ឲ្យមកនេះទេ?

ម៉ៅ ៖ អត់ទេ ។

ធានី ៖ កាលហ្នឹងមីងនៅជប់គគីរធ្វើអីគេ?

ម៉ៅ ៖ ចា៎! គេដឹកមក ។

ធានី ៖ គេដឹកមកស្នាក់នៅហ្នឹង?

ម៉ៅ ៖ ចា៎!

ធានី ៖ ហើយមីងនៅមេបុណ្យក៏គេដឹកមកដែរ?

ម៉ៅ ៖ ចា៎!

ធានី ៖ មេបុណ្យហ្នឹងកន្លែងនៅណាវិញ?

ម៉ៅ ៖ កន្លែងមេបុណ្យ បៀតប្រាសាទបន្ទាយឆ្មារហ្នឹង ។

ធានី ៖ អូ! មេបុណ្យ ។

ម៉ៅ ៖ ប៉ុនគ្រាន់គេថាបេះ ។

ធានី ៖ ជិតនេះដែរ?

ម៉ៅ ៖ ចា៎! ជិតនេះតើ ។ ប៉ុនកាលហ្នឹងហ៊ុនស៊ីប៉ិច ហ៊ុនសែនគេមិនប្រកាសអ្នកអត់ឈ្នះចាញ់ យើងចុះមក ប៉ុន្តែខ្មែរក្រហមគេដាក់ម្ដុំៗ ។ ដល់តែពេលយើងមិនបោះឆ្នោត៩៣ យើងបោះឲ្យហ៊ុនស៊ីប៉ិចឈ្នះ ដល់ឈ្នះលេងគាត់ដេញយើងចេញយកគោ យកមាន់ យកជ្រូក អីអស់ បោះឆ្នោតឲ្យគាត់ឈ្នះ ដេញយកគោនិយាយទៅស្ទើក៏យកទាំងអស់ ។

ធានី ៖ គេយកធ្វើអីមីងដឹងទេ?

ម៉ៅ ៖ ចុះអ្នកណាទៅដឹងទេ ឈើ ផ្ទះ មាន់ ទា ជ្រូកអីគេយកទាំងអស់ យើងឡើងតែខ្លួន ។

ធានី ៖ ទៅណាវិញ?

ម៉ៅ ៖ អឺ! កាលហ្នឹងគេដឹក កាកបាទគេដឹកយកយើងទៅចូលយើងហ្នឹងកងវ៉ា គេហៅជនភៀសសឹក ហ្នឹង ។

ធានី ៖ កងវ៉ា?

ម៉ៅ ៖ ហ្នឹងដឹក ។

ធានី ៖ នៅឆ្នាំ៩១ ៩៣ បោះឆ្នោតហើយហ្នឹង?

ម៉ៅ ៖ ៩៤ហើយ ។

ធានី ៖ ៩៤ហើយ?

ម៉ៅ ៖ ចូល៩៤ ។

ធានី ៖ ចឹង៩៤មីងនៅនេះ ហើយគេមកយកទ្រព្យសម្បត្តិមីងអស់ ក៏មីងរត់ទៅថៃម្ដងទៀត?

ម៉ៅ ៖ យើងបោះឆ្នោតហើយ ។

ធានី ៖ បោះឆ្នោតហើយរត់ទៅថៃវិញ?

ម៉ៅ ៖ អត់រត់ទៅថៃទេ រត់ទៅស្ដៅ ប៉ុនមិនដឹងឆ្នាំប៉ុន្មានទេ ប៉ុនដឹងថាបោះឆ្នោតហើយ ។

ធានី ៖ បោះឆ្នោតហើយបានរត់ទៅស្ដៅ?

ម៉ៅ ៖ គេកាលហ្នឹងគេមិនដកកាំភ្លើងពីខ្មែរក្រហម គ្រួសារខ្ញុំមិនមានអីទេ សូម្បីតែគោពពែអីក៏គេដក យកអស់ដែរគេមិនឲ្យយើងទេ ។

ធានី ៖ ហើយបន្ទាប់មកទៀត នៅឆ្នាំ៩៤បានរត់មកនៅបន្ទាយឆ្មារនេះទៅ?

ម៉ៅ ៖ វាចុងឆ្នាំ ដើមឆ្នាំ ។

ធានី ៖ ហើយពេលដែលមីងមកដល់ម៉េចដែរមីង មកដល់ភូមិដំបូង?

ម៉ៅ ៖ មកដល់ភូមិនេះ លំបាកលើសលំបាក ខាងខ្មែរក្រហមថាវាលំបាក មកនៅនេះសំពះអាគ្រាក់ សំពះអីគេសុំទឹកគេដឹក ដាក់ទឹកម៉ាកាដុងចឹង ដាក់មកយើងអត់មានកង់មានអី អត់ទឹក គេយក យើងមកដាក់ហ្នឹង ។

ធានី ៖ ចឹងនៅកន្លែងហ្នឹងអត់មានទឹកមានអីហូបទេ?

ម៉ៅ ៖ អត់មានទេ ឆ្នាំហ្នឹងអត់មានទេ កាកបាទគេដឹកឲ្យ ប៉ុនហូបមិនគ្រប់គ្នាច្រើន ។

ធានី ៖ ចឹងបានអីហូប?

ម៉ៅ ៖ នោះទៅដឹកនៅស្រះ២ ។

ធានី ៖ ចុះដល់រាល់ថ្ងៃទឹកហូបគ្រប់គ្រាន់ទេ?

ម៉ៅ ៖ ឥឡូវបានពួកអង្គការ បានជួយបានស្រះ២ ។

ធានី ៖ ស្រះណាខ្លះទៅ?

ម៉ៅ ៖ នេះស្រះទឹកស្អាតនេះ ពួកស៊ីដូគេជួយ ហើយពួកអឺ!ស្អឹគណៈបក្សគេជួយ ។

ធានី ៖ ចុះមីងថាស្គាល់តាចៀម មីងស្គាល់ពេលណាទៅ?

ម៉ៅ ៖ អ្នកណាគេ ។

ធានី ៖ តាចៀមនោះ?

ម៉ៅ ៖ អង្កាល់កាលយើង ខ្ញុំដែលចេញពីបឹងត្រកួនដូចខ្ញុំថាគេរៀបដូរកងទ័ព ។

ធានី ៖ ពេលមីងចេញពីបឹងត្រកួននៅម៉ាឡៃហ្នឹង?

ម៉ៅ ៖ ចាំ!

ធានី ៖ បឹងកាលហ្នឹងតាចៀមគាត់ធ្វើអីគេ?

ម៉ៅ ៖ ប្ដីខ្ញុំបានដឹង ព្រោះអីខ្ញុំមានគ្រួសារហើយ ខ្ញុំព្រួគេនិយាយ ។

ធានី ៖ ស្គាល់តាចៀម ចុះក្រៅពីតាចៀម ស្គាល់អ្នកផ្សេងទៀត?

ម៉ៅ ៖ ខ្ញុំមិនសូវស្គាល់ទេ ព្រោះអីខ្ញុំមានកូនៗ ខ្ញុំលែងដើរព្រួគេថាកៗ គេថាខ្វៗហ្នឹងគេ ។

ធានី ៖ បឹងមីងមកនៅ៥១៩៧រហូតដល់ឆ្នាំ៩៨?

ម៉ៅ ៖ ដល់រហូត ។

ធានី ៖ រហូតដល់ឥឡូវហ្នឹង?

ម៉ៅ ៖ រហូតឥឡូវហ្នឹង ។

ធានី ៖ ចុះរាល់ថ្ងៃមីងធ្វើការងារអីដែរ?

ម៉ៅ ៖ ចាំ! អត់នៅផ្ទះ ។

ធានី ៖ នៅផ្ទះ?

ម៉ៅ ៖ នៅផ្ទះ ។

ធានី ៖ ឪពុកមីងឈ្មោះអីគេ?

ម៉ៅ ៖ ឪពុកខ្ញុំឈ្មោះ យកជីតាដែរ?

ធានី ៖ ចាំ!

ម៉ៅ ៖ ខ្ញុំដាក់អ៊ិន គាត់ដាក់ អ៊ិន ហ៊ិនបឹងទៅ ។

ធានី ៖ ឪពុកមីងអ៊ិន ហ៊ិន?

ម៉ៅ ៖ ចាំ!

ធានី ៖ គាត់នៅរស់ហើយស្លាប់ហើយ?

ម៉ៅ ៖ ស្លាប់ហើយ ។

ធានី ៖ ស្លាប់ពេលណាដែរ?

ម៉ៅ ៖ ទេ! ទើបស្លាប់ដែរ ស្លាប់ប៉ុន្មាន៣-៤ឆ្នាំ ។

ធានី ៖ ៣-៤ឆ្នាំ ចឹងឆ្នាំ២០០៦?

ម៉ៅ ៖ មិនដឹងដែរ ខ្ញុំមិនបានទៅបុណ្យគាត់ផង ។

ធានី ៖ តែមីងប្រាប់៣-៤ឆ្នាំ?

ម៉ៅ ៖ ចាំ!

ធានី ៖ ចុះម្តាយមីងឈ្មោះអីគេ?

ម៉ៅ ៖ មិនដឹងគាត់ដាក់អីផង ប៉ុនខ្ញុំដឹងតាខ្ញុំឈ្មោះតាភួង ។

ធានី ៖ តាភួង ចុះម្តាយឈ្មោះអីគេ?

ម៉ៅ ៖ ឈ្មោះ យ័ន្ត ។

ធានី ៖ ភួង យ័ន្តចឹង?

ម៉ៅ ៖ ចាំ!

ធានី ៖ គាត់នៅរស់ទេ?

ម៉ៅ ៖ រស់ ។

ធានី ៖ រស់នៅណាវិញ?

ម៉ៅ ៖ នៅព្រៃដើង ។

ធានី ៖ ភូមិអីគេ?

ម៉ៅ ៖ ភូមិព្រៃដើង ។

ធានី ៖ ភូមិព្រៃដើង ឃុំអីគេ?

ម៉ៅ ៖ គោកព្រេច ។

ធានី ៖ គោកព្រេច ស្រុកអីគេ?

ម៉ៅ ៖ គិរីវង់ ។

ធានី ៖ នៅស្រុកកំណើតរបស់មីងហ្នឹង?

ម៉ៅ ៖ ចាំ!

ធានី ៖ បងប្អូនប៉ុន្មាននាក់ដែរមីង?

ម៉ៅ ៖ ខ្ញុំ៦នាក់ ។

ធានី ៖ ៦នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ម៉ៅ ៖ ស្រី៣ ប្រុស៣ ។

ធានី ៖ នៅរស់ទាំង៣ទេ?

ម៉ៅ ៖ ចាំ!

ធានី ៖ នៅរស់ទាំងអស់?

ម៉ៅ ៖ ចាំ!

ធានី ៖ ចឹងមីងមានឈ្មោះបដិវត្តទេ?

ម៉ៅ ៖ ខ្ញុំឈ្មោះកំណើតឈ្មោះម៉ៅ ។

ធានី ៖ អីគេម៉ៅ?

ម៉ៅ ៖ អ៊ិន ។

ធានី ៖ អ៊ិន ម៉ៅ?

ម៉ៅ ៖ ចាំ!

ធានី ៖ ដល់ពេលឈ្មោះបដិវត្តមានទេ?

ម៉ៅ ៖ មានឈ្មោះអ៊ិន សាម៉េន ។

ធានី ៖ អ៊ិន សាម៉េន?

ម៉ៅ ៖ អឺ!

ធានី ៖ ស្រុកកំណើតនៅអីគេមីងនិយាយមិញ?

ម៉ៅ ៖ គិរីវង់ ។

ធានី ៖ នៅភូមិអីគេមីងភូមិ?

ម៉ៅ ៖ ព្រៃដើង ។

ធានី ៖ ឃុំអីគេចេះ?

ម៉ៅ ៖ គោកព្រេច ។

ធានី ៖ អូ! ខ្ញុំស្គាល់ហើយគោកព្រេចហ្នឹង ។

ម៉ៅ ៖ ជិតកំពែងហ្នឹង ។

ធានី ៖ ចាំ! ជិតកំពែង ប៉ុន្តែទៅខាងមុខ ។

ម៉ៅ ៖ បើប្អូនចូលពីខាងលិច ប្អូនឯងដើរពីខាងលិចភ្នំ គោកព្រេចនៅខាងជើងភ្នំ ។

ធានី ៖ ចា៎! ត្រូវហើយបើជិះទៅមុខទៀត ទៅដល់ស្អីគេឃុំអីគេ ស្រណាល ។

ម៉ៅ ៖ ខាងត្បូងភ្នំ?

ធានី ៖ ចា៎!

ម៉ៅ ៖ ខាងត្បូងភ្នំ ខ្ញុំអត់ដែលទៅ ។

ធានី ៖ អត់ទេ ឃុំម្តុំខាងវត្តព្រះធាតុ មិនមែនគោកព្រេចទេ ។

ម៉ៅ ៖ ឃុំក្បាលដំរី ឃុំ ។

ធានី ៖ ឃុំក្បាលដំរីនៅខាងលិចវិញទេ ។

ម៉ៅ ៖ ដូចតាពូងម៉េច ។

ធានី ៖ ហ្នឹងហើយ សំពោចៗមិនមែនទេឃុំមួយទៀតទេ ។

ម៉ៅ ៖ ក្រាំងតាម៉ូង មិនដឹងស្អីទេ ប្អូនភ្លេចអស់ហើយ ។

ធានី ៖ មួយទៀតៗនៅកន្លែងចុងៗមាត់ៗហ្នឹងជាប់គោកព្រេចហ្នឹងដែរ ។

ម៉ៅ ៖ ហ្នឹងហើយជាប់គ្នា ប៉ុននៅដូចភ្លេចភូមិហ្នឹងអស់ ។

ធានី ៖ នៅឃុំគោកព្រេច ស្រុកគិរីវង់?

ម៉ៅ ៖ អឺ!

ធានី ៖ រាល់ថ្ងៃមីងនៅណាវិញ?

ម៉ៅ ៖ រាល់ថ្ងៃនៅហ្នឹងឯង ។

ធានី ៖ ភូមិឃុំអីដែរ?

ម៉ៅ ៖ ភូមិថ្មដែកកេះ ។

ធានី ៖ ឃុំអីគេ?

ម៉ៅ ៖ បន្ទាយឆ្មារ ។

ធានី ៖ ម៉េចបានគេដាក់ថ្មដែកកេះចឹង?

ម៉ៅ ៖ អត់ដឹងដែរ ។

ធានី ៖ ឃុំបន្ទាយឆ្មារ ស្រុកអីគេ ស្រុកបន្ទាយឆ្មារដឹង?

ម៉ៅ ៖ ថ្មពួក ។

ធានី ៖ ថ្មពួក ខេត្តអីគេ?

ម៉ៅ ៖ បន្ទាយមានជ័យ ។

ធានី : មីងកាលពេលមីងមកដល់ភូមិនេះដំបូងមានអ្នកភូមិរស់នៅហើយ ឬក៏អត់មានទេ?

ម៉ៅ : អត់ទេ ។

ធានី : ជាតំបន់យ៉ាងម៉េចភូមិហ្នឹងដំបូង?

ម៉ៅ : ព្រៃ ។

ធានី : ចុះម៉េចបានភូមិហ្នឹង គេដាក់ថ្មដែកកេះចឹង មីងដឹងអត់ ដើមទង?

ម៉ៅ : អត់ដឹងដែរ ។

ធានី : ម៉េចគេហៅចឹង?

ម៉ៅ : មិនដឹងអី ពួកគេថាម៉េចទេអ្នកអារឈើបាត់ដែកកេះម៉េចទេ ខ្ញុំមិនសូវដឹងដែរ ។

ធានី : តែមីងដឹងប៉ុន្មាន ជួយប្រាប់តិចមើល ថាប្រវត្តិភូមិហ្នឹង?

ម៉ៅ : អត់ដឹងទេប្អូន ខ្ញុំអត់ដឹងដែរ ពួកតែគេហៅដែកកេះ ហៅតាមគេចឹងម៉ង ។

ធានី : ពួកអ្នកអារឈើបាត់ដែកកេះ?

ម៉ៅ : ចា៎!

ធានី : ចឹងកន្លែងហ្នឹងសំបូរអ្នកអារឈើ?

ម៉ៅ : ចា៎! វាដឹងពិតមិនពិតទេ ពួកតៗគ្នា ខ្ញុំមិនដឹងដែរពួកតៗគ្នា ។

ធានី : បាត់ដែកកេះ ជាប់ភូមិថ្មដែកកេះ ។

ម៉ៅ : ថ្មដែកកេះ ។

ធានី : ចឹងភូមិហ្នឹងបង្កើតៗយូរហើយ?

ម៉ៅ : បង្កើតកាលខ្ញុំមក ដែលថា៩៨ហ្នឹង ។

ធានី : ចឹងទើបបង្កើត១៩៩៨នេះទេ ។ មីងៗមានអីចង់សួរខ្ញុំទៀតទេ នៅអ្វីដែលខ្ញុំថាដូចថាចង់សំណូមពរអី?

ម៉ៅ : ខ្ញុំមិនមានអីទៀតទេ គ្រាន់តែនិយាយនេះហ្នឹងសំណូមពរអីទេ គ្រាន់ថាយើងរស់នៅនេះមកក្រោយពីតស៊ូមកនៅគេដឹកមកនៅគេចែកដីឲ្យទៅក៏គេចែកដី គេហៅដីស្អីគេ ដីសមាសហគមន៍ហើយសមាគមន៍ម៉េច ។

ធានី : ដីសម្បទាន?

ម៉ៅ : ហ្នឹងហើយ ដីព្រៃសហគមន៍ ដល់ចឹងទាហានយកអស់ទៅ ប្រជាជនអត់មានអីធ្វើទេ ។

ធានី : ចុះក្រែងគ្រួសារមីងធ្វើទាហានដែរ ម៉េចក៏មិនអាចយកបាន?

ម៉ៅ : អឺ! ធ្វើទាហានគេយកធ្វើបន្ទាយៗ តើ
គេយកធ្វើបន្ទាយ គេចែកម៉េចបានយើងប្រជាជនទាហាន យើងឈ្មោះទាហាន
ប៉ុន្តែយើងមិនមែននៅកងជាមួយគេទេណា ។

ធានី : ចឹងគាត់ទាហានផ្សេងទាហាន?

ម៉ៅ : ចាំ! កងផ្សេង ។

ធានី : គាត់រំសាយហើយ?

ម៉ៅ : ចាំ! រំសាយហើយ ។

ធានី : ហើយចឹងមីងមានអីចង់និយាយបន្ថែមទៀតអត់?

ម៉ៅ : ខ្ញុំគ្មានអីទេ ថាយើងគ្មានស្អីទេ ទោះបីសំណូមពរអីក៏វាមិនបានអី និយាយឲ្យខ្ចីទៅ ។

ធានី : មីងដូចថាតាំងពីសម័យហ្នឹងរហូតមកដល់ឥឡូវ
មីងធ្លាប់បានជួយអ្នកណាគេឲ្យរួចជីវិតអីអត់?

ម៉ៅ : មិនមានទេ សុទ្ធតែយើងត្រូវសះឲ្យរស់ដូចតែគ្នា ។

ធានី : ចុះមានជួយឲ្យជាចំណីអាហារអីៗ?

ម៉ៅ : អត់ទេ ព្រោះអីខ្ញុំទន់ខ្សោយដែរ ដូចខ្ញុំថាចឹង យើងអ្នកគេមិនទុកចិត្ត យើងមិនអាចជួយអ្នកណាបាន ។

ធានី : ចឹងមីងកាលសម័យហ្នឹងអត់បានធ្វើការងារអីទេ?

ម៉ៅ : អត់ទេ ព្រោះអីយើងក្នុងអង្គការតាមដានគេ ។

ធានី : ហេតុអីបានមីងទៅក្នុងអង្គការតាមដាន?

ម៉ៅ : ព្រោះអីបងប្អូនយើងសុទ្ធតែទាហានប៉ូលីស ។

ធានី : តែអ៊ំមីងម្នាក់សោះធ្វើទាហាន មានអ្នកណាគេផ្សេង?

ម៉ៅ : អត់មានម្នាក់ទេ ម៉ាពូជឪខ្ញុំទាហានប៉ូលីសទាំងអស់ ។

ធានី : ចឹងគេយកទៅសម្លាប់ទាំងអស់ ។ តែដល់ពេលគេតាមដានមីង ហេតុអីក៏មីងអត់អី គេថាអត់អី?

ម៉ៅ : ដល់ចឹងទៅយើងអត់មានដាក់ឈ្មោះម៉ែឪយើងផង យើងដាក់ថាស្លាប់រហូត ។

ធានី : ដាក់ឈ្មោះឪម៉ែដែរអត់ៗទេ?

ម៉ៅ : អត់ទេ ដាក់ប៉ុនយើងអត់យកឈ្មោះណាណែដាក់ទៅ ។

ធានី : ដាក់ឈ្មោះអីគេកាលសម័យធ្វើប្រវត្តិរូប?

ម៉ៅ ៖ ចាំ! ខ្ញុំឈ្មោះៗមកដដែល ប៉ុនយើងដាក់ឈ្មោះផ្សេងៗម្ដងដាក់ម៉ែឈ្មោះនេះ ម្ដងឪឈ្មោះនេះទៅ ធម្មតាយើងយកឈ្មោះគេមកដាក់យើងមិនចាំឈ្មោះ ។

ធានី ៖ ត្រូវហើយ យើង គេអត់ថាអីដែរ យើងម្ដងដាក់ឈ្មោះនេះម្ដងដាក់ឈ្មោះនោះ?

ម៉ៅ ៖ ចុះយើងម្ដងចូលកងនេះ ម្ដងចូលកងនោះ ។

ធានី ៖ ចឹងគេអត់ចាប់អារម្មណ៍ ។ ចុះមីងដែលធ្លាប់ទៅលេងស្រុកទេ?

ម៉ៅ ៖ ខ្ញុំបានគ្រួសារហើយធ្លាប់ទៅលេងស្រុកបាន២ដង ។

ធានី ៖ អូ! ធ្លាប់ទៅលេងម្ដាយដែរ ។

ម៉ៅ ៖ ចាំ!

ធានី ៖ កាលម៉ាហឹកមុន ឪពុកមីងស្លាប់ហ្នឹងហេតុអីបានមីងអត់បានទៅ?

ម៉ៅ ៖ អត់លុយ យើងឯករាជ្យហើយ ប៉ុន្តែយើងអត់លុយ ។

ធានី ៖ កាលទៅលេងស្រុកលើកដំបូងមានអារម្មណ៍ម៉េចដែរ?

ម៉ៅ ៖ អត់ចេះនៅ ។

ធានី ៖ ម៉េចចឹង?

ម៉ៅ ៖ យើងធ្លាប់នៅព្រៃ ដល់ទៅនៅវាលនៅមិនកើត ។

ធានី ៖ អូ! ធ្លាប់នៅព្រៃ?

ម៉ៅ ៖ ចាំ! ដឹចស្មៀតយើងអត់ចេះនៅ ។

ធានី ៖ អូ! មែននៅព្រៃដីទូលាយធំអីចឹង?

ម៉ៅ ៖ ចាំ!

ធានី ៖ ដល់ពេលមកនេះដឹចស្មៀតតូចៗ?

ម៉ៅ ៖ ចាំ!

ធានី ៖ ចុះម្ដាយមីងយល់ថាម៉េចដែរ ពេលទៅជួបដំបូង?

ម៉ៅ ៖ គាត់អត់មានបន្ទោសអីផង ។

ធានី ៖ តែមីងមានដឹងថាមីងបាត់ខ្លួនអី?

ម៉ៅ ៖ ម៉ែខ្ញុំមករកខ្ញុំជាប់គុក២ដងដែរ ។

ធានី ៖ ទៅរកនៅណាវិញ?

ម៉ៅ ៖ ចាំ! ទៅរកកាលខ្ញុំនៅម៉ាឡៃ ទៅមកមិនបានជួបផង គេចាប់ជាប់គុកយកទៅដាក់គុក ។

ធានី ៖ ចឹងកាលហ្នឹងម៉េចបានគាត់ដឹងមីងនៅម៉ាឡៃ ហើយគាត់តាមរក?

ម៉ៅ ៖ ឮសូរតាមដូចគេតេ់ៗចេញពីខ្មែរក្រហមទៅគេខ្សឹបប្រាប់ ដល់គេខ្សឹបប្រាប់ចឹងទៅគេថា ដល់នេះគេតាមដានទៅដឹងម៉ែខ្ញុំមកស្រុកគេចាប់ដាក់គុក ។

ធានី ៖ មកៗដល់ស្រុកម៉ាខ្មែរទេ?

ម៉ៅ ៖ អត់ដល់ទេ ។

ធានី ៖ តែម្ដាយមីងចេញពីស្រុកភ្នាម គេចាប់ភ្លាម?

ម៉ៅ ៖ ដឹងគេចាប់គាត់ណាផង ។

ធានី ៖ គាត់ប្រាប់?

ម៉ៅ ៖ ចា៎!

ធានី ៖ ហើយដល់ពេលបានជួបមីង គាត់មានអារម្មណ៍ម៉េចទៅ មីងអីមានអារម្មណ៍ម៉េច?

ម៉ៅ ៖ មានអី មានតែយំហ្នឹងហើយ ។

ធានី ៖ ម៉េចទៅរន្ធត់យ៉ាងម៉េចខ្លះ ជួយប្រាប់ពេលហ្នឹងមានអារម្មណ៍?

ម៉ៅ ៖ អូយ! ប្អូនអើយមនុស្សយើងវាអរក៏យំ សើច ភ័យក៏យំដែរ វាមានតែប៉ុនហ្នឹង ។

ធានី ៖ ហើយគាត់ម្ដាយមីង គាត់មាននិយាយថាស្មានតែស្លាប់ហើយ?

ម៉ៅ ៖ គេនិយាយទាំងអស់ហ្នឹង បងប្អូនដីដូនមួយអីទាំងអស់ ។

ធានី ៖ ហើយទៅដល់គេមានរៀបចំធ្វើស្អីៗឲ្យមីងខ្លះអត់ទេ?

ម៉ៅ ៖ អត់ទេប្អូនន ក្រុមគ្រួសារខ្ញុំក្រ ។

ធានី ៖ គ្រាន់តែជួបជុំគ្នា?

ម៉ៅ ៖ ម្ដាយឪពុកខ្ញុំក្រ ខ្ញុំក្រអត់មានលទ្ធភាព ។

ធានី ៖ អត់ទេចង់និយាយថា គ្រាន់តែជួបជុំគ្នាក្នុងផ្ទះហ្នឹងអីចឹង?

ម៉ៅ ៖ ហ្នឹង ។

ធានី ៖ នៅបានប៉ុន្មានថ្ងៃ មីងទៅលេងផ្ទះ?

ម៉ៅ ៖ ខ្ញុំទៅនៅមិនបានយូរដែង មកបានប៉ុន្មាន ។

ធានី ៖ ៣-៤ថ្ងៃត្រឡប់មកវិញ?

ម៉ៅ ៖ ចា៎! អត់ចេះនៅ ។

ធានី ៖ ហើយទៅលេងលើកក្រោយ លេងដំបូងឆ្នាំប៉ុន្មាន?

ម៉ៅ ៖ ទៅកាល៩៨ហ្នឹង ។

ធានី ៖ គ្រាន់តែបែកភ្លាម ទៅភ្លាម នឹកផ្ទះ?

ម៉ៅ ៖ ចាំ!

ធានី ៖ នឹកម្ដាយ ឪពុក?

ម៉ៅ ៖ ហ្នឹង ទៅឪពុកខ្ញុំនៅ ។

ធានី ៖ ដល់ពេលហើយ ដល់ក្រោយមកទៀតទៅលេងពេលណាទៀត?

ម៉ៅ ៖ ខ្ញុំទើបទៅប៉ុន្មានឆ្នាំមុន ២-៣ឆ្នាំ ។

ធានី ៖ ពេលឪពុកស្លាប់ហើយ?

ម៉ៅ ៖ ចាំ! ឪពុកស្លាប់ហើយ ទើបទៅបាន២ឆ្នាំ ។

ធានី ៖ ចឹងនៅឆ្នាំ២០០៨ ឥឡូវ២០១០?

ម៉ៅ ៖ ២០០០អឺ!

ធានី ៖ ២០០៩?

ម៉ៅ ៖ អឺ! ២០០៨ត្រូវហើយ ។

ធានី ៖ ២០០៨ ទៅលេងផ្ទះម្ដងទៀត ពេលហ្នឹងឪពុកស្លាប់ហើយ? ហើយគាត់ស្វាគមន៍ដូចមុនទេ?

ម៉ៅ ៖ មានអី ។

ធានី ៖ ហើយនៅបានប៉ុន្មានថ្ងៃ?

ម៉ៅ ៖ ខ្ញុំទៅបានប៉ុន្មានថ្ងៃទេ គេតេស្ដហៅគ្រួសារខ្ញុំអង្គការសុំជួបក៏មកវិញ ។

ធានី ៖ ប៉ុន្មានថ្ងៃ ២-៣ថ្ងៃ?

ម៉ៅ ៖ ៣ថ្ងៃប៉ុននោះឯងប្អូន ។

ធានី ៖ ៣ថ្ងៃ ។ មីងមិញថាកូនមីងមានប៉ុន្មាននាក់?

ម៉ៅ ៖ កូន៧ ។

ធានី ៖ កូន៧នាក់?

ម៉ៅ ៖ ចាំ!

ធានី ៖ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ម៉ៅ ៖ ស្រី១ ប្រុស៦ ។

ធានី ៖ ចឹងថាអត់មានកូនស្រី ។ គ្រួសារមីងឈ្មោះអីគេ អូ!ប្រាប់ឈ្មោះម្ដងហើយ ។ ចឹងមីងមានអីចង់សួរ ចង់បន្ថែមសំណួមពរអីអត់?

ម៉ៅ ៖ គ្មានសំណួមពរអីទេ វាហួសពីមាត់ហើយ ។

ធានី ៖ ចា៎! ចឹងអរគុណមីងច្រើនៗ

«ចប់»